## មជ្ឈមណ្ឌលឯកសារកម្ពុជា

## សម្ភាសន៍ជាមួយ ញ៉ាំង សែន ហៅ ជា សែន ភេទប្រុស អាយុ៥៩ឆ្នាំ

## មុខងារសម័យខ្មែរក្រហមៈ គណៈចំការកៅស៊ូ និងចំការកប្បាស

## ស្រុកកំណើតនៅភូមិកែត ឃុំញ៉ាំង ស្រុកអណ្តូងមាស ខេត្តរតនគិរី

## រស់នៅភូមិសែនសុខ ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ

## ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៣

## សម្ភាសន៍ដោយៈ ឡុង ដានី

## ០១:៣៥:២០

## ៤០ទំព័រ

ដានីៈ អីចឹងដំបូងលោកពូខ្ញុំចង់ស្គាល់ឈ្មោះពេញ ឈ្មោះអីដែរ?

សែនៈ ឈ្មោះ ញាង សែន ពីដើម ជា សែន ក្នុងសៀវភៅគ្រួសារ ក្នុងអត្តសញ្ញាណបណ្ណគេហៅ ញាង សែន រហូត។

ដានីៈ «ញ» ដាក់ «ា»?

សែនៈ «ញ» ដាក់បណ្តក់ « ” » ។

ដានីៈ ញ៉ាំង សែន។

សែនៈ សែន។

ដានីៈ កាលពីឈ្មោះក្នុងបញ្ជីជាតិតាំងពីតូចឈ្មោះ?

សែនៈ កាលនោះមិនទាន់មាន កាលខ្ញុំនៅរតនគិរី ខ្ញុំនៅរតនគិរីតូចៗ ឪពុកខ្ញុំធ្វើទាហានមកតាំងពីតូចមក តាំងពីអាយុ១៥មក។

ដានីៈ កាលពីមុនមកលោកពូដាក់ឈ្មោះ ជា សែន?

សែនៈ នោះមិនទាន់ជាផ្លូវការទេ ដល់ពេលធ្វើទាហានខ្ញុំអត់ស្គាល់ជីតា ក៏ដាក់ឈ្មោះពុក។

ដានីៈ ញ៉ាំង ហ្នឹងឈ្មោះឪពុក?

សែនៈ បាទ!

ដានីៈ ជា ឈ្មោះជីតា?

សែនៈ បាទ!

ដានីៈ លោកពូអាយុប៉ុន្មានហើយសព្វថ្ងៃ?

សែនៈ ខ្ញុំតាំងពី៤៤មក។

ដានីៈ ១៩៤៤។ ៤០-២០០០វា៦០។ ៥៤ ឬ៤៤?

សែនៈ ៤៤។

ដានី: កើតឆ្នាំ១៩៨៤ ឆ្នាំអីឆ្នាំខ្មែរយើង?

សែនៈ អត់ស្គាល់ ។

ដានី: ឆ្នាំសត្វ? គោ, ជ្រូក, ខ្លា?

សែនៈ នាគ ។

ដានី: ឆ្នាំរោង?

សែនៈ រោង មិនដឹងម្សាញ់ អត់ចាំ ។

ដានី: គ្រាន់តែដឹងថាដាក់ឆ្នាំ១៩៨៤?

សែនៈ បាទ!

ដានី: ហើយលោកពូជនជាតិខ្មែរ ឬជនជាតិ?

សែនៈ ជនជាតិចារ៉ាយ ។

ដានី: ស្រុកកំណើតកើតជានៅភូមិ ឃុំ ស្រុកអីដែរ?

សែនៈ នៅភូមិកែត ឃុំញ៉ាង ស្រុកអណ្ដូងមាស ខេត្តរតនគិរី ។

ដានី: អីចឹងលោកពូស្គាល់អ៊ំ ចៀម ដែរ?

សែនៈ ស្គាល់ ប្អូនខ្ញុំ ប្អូនជីដូនមួយ ។

ដានី: ខ្ញុំទៅជួបគាត់នៅម៉ាឡៃដែរ ។

សែនៈ កូនខ្ញុំទៅការកូនគាត់ទើបតែមក ។

ដានី: កូនគាត់ការ?

សែនៈ បាទ! ការកូនគាត់ ហៅខ្ញុំទៅ តែកូនខ្ញុំចង់ទៅ ខ្ញុំឲ្យទៅ ថវិការតិចពេកឲ្យកូនទៅ ។

ដានី: អីចឹងអ៊ំចៀម ហើយនិងលោកពូត្រូវជាបងប្អូនជីដូនមួយ គាត់ប្អូនលោកអ៊ំទេ?

សែនៈ ប្អូន ។

ដានី: អីចឹងអ៊ំ ហើយនិងអ៊ំចៀម បងប្អូន ហើយគាត់អាយុតិចជាងអ៊ំទេ?

សែនៈ តិចទេ មានបងមួយនៅហ្នឹងដែរ នៅភូមិពង្រ ។

ដានី: បងណា?

សែនៈ នៅម៉ាឡៃ បងដៀន ។

ដានី: ដៀន ហ្នឹងត្រូវជាបងអ៊ំបង្កើត?

សែនៈ បាទ! បងបង្កើត ។

ដានី: ហើយគ្រួសារអ៊ំឈ្មោះអីដែរ? ប្រពន្ធ?

សែនៈ ប្រាក់ សុភី ។

ដានី: គាត់អាយុប៉ុន្មានដែរ?

សែន: ចូលហាហើយ ឆ្នាំរក ។

ដានី: ប្អូនអ៊ំច្រើន?

សែន: ច្រើន ។

ដានី: ប្រហែលប៉ុន្មានឆ្នាំទៅ?

សែន: ចង់ជាប់១០ឆ្នាំ ។

ដានី: ខ្ទង់ហាសិបជាង?

សែន: បាទ!

ដានី: ហើយអ៊ំមានកូនចៅប៉ុន្មាននាក់?

សែន: ៥នាក់ ។

ដានី: ស្រីប៉ុន្មាន ប្រុសប៉ុន្មានទៅ?

សែន: ស្រីទាំងអស់ ។

ដានី: គាត់ធំៗអស់ហើយ?

សែន: ធំអស់ហើយ ទី១បានប្តីហើយ ។

ដានី: មួយគាត់មានគ្រួសារហើយ ៤នាក់ទៀតនៅរៀន ឬក៏ឈប់ហើយ?

សែន: នៅរៀន៣នាក់ ។

ដានី: គាត់បានរៀនដល់ថ្នាក់ណា?

សែន: មួយថ្នាក់ទី៩ តែវាលំបាកទៅមកពេក អត់អីទៅឥឡូវឈប់ទៀត នៅសល់២នាក់ ។

ដានី: គាត់រៀននៅណា?

សែន: រៀនត្រពាំងប្រាសាទ អត់មានអីទៅ ។

ដានី: ថ្នាក់ទី៩?

សែន: ទី៩ ។

ដានី: ហើយ២នាក់ទៀតដល់ថ្នាក់ទីប៉ុន្មានហើយ?

សែន: មួយដល់ថ្នាក់ទី៨ចូលទី៩ ហើយមួយថ្នាក់ទី៤ពៅគេ ។

ដានី: ពៅថ្នាក់ទី៤ រៀននៅនេះទេ?

សែន: នៅនេះ ។

ដានី: សព្វថ្ងៃនេះអ៊ំរស់នៅក្នុងភូមិអីដែរ?

សែន: ភូមិសែនសុខ ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។

ដានី:	ឪពុកអ៊ំគាត់ឈ្មោះអីដែរ?

សែន:	ញ៉ាំង តែអត់ស្គាល់ជីតាទេ ។

ដានី:	ឪពុកឈ្មោះ ញ៉ាំង?

សែន:	បាទ!

ដានី:	គាត់នៅរស់ ឬខូចហើយ?

សែន:	ខូចហើយ ខូចអត់ឃើញផងខ្ញុំនៅធ្វើទាហាន ។

ដានី:	ហើយម្ដាយគាត់ឈ្មោះអីដែរ?

សែន:	ម្ដាយដើស ។

ដានី:	ហើយគាត់នៅរស់ឬក៏?

សែន:	ស្លាប់ហើយ ។

ដានី:	ស្លាប់តាំងពីអង្កាល់?

សែន:	តាំងពី៨១ អត់ឃើញដែរ តាំងពី៨១ ។

ដានី:	អ៊ំមានបងប្អូនបង្កើតប៉ុន្មាននាក់ទៅ?

សែន:	បងប្អូន៥នាក់ ប្រុស៤ ស្រី១ ។

ដានី:	ហើយគាត់៤នាក់ប្រុសគាត់នៅណា?

សែន:	បងមួយនៅម៉ាឡៃ ។

ដានី:	ឈ្មោះអីនៅម៉ាឡៃ?

សែន:	ឈ្មោះដៀង ។

ដានី:	មួយនៅណាទៀត?

សែន:	បងដេញ នៅស្រុកកំណើត ភូមិកែត ហើយប្អូនមួយនៅវៀតណាម ។

ដានី:	គាត់នៅវៀតណាម?

សែន:	បាទ!

ដានី:	ម៉េចបានគាត់នៅវៀតណាមអីចឹង?

សែន:	នៅភូមិជាប់គ្នាអីចឹង ពីដើមភូមិគេជាប់ព្រំដេន ដល់នេះគេកាត់ផ្លូវចូលទៅនោះ ។

ដានី:	គេកាត់ឆ្នាំណាដែលចូលទៅព្រំដែនខាងវៀតណាម?

សែន:	មិនដឹងឆ្នាំណាអត់បានសួរគេ ខ្ញុំទៅឃើងចប់ហើយ ។

ដានី:	កាលពីអ៊ំនៅស្រុកកំណើតដីហ្នឹងនៅស្រុកខ្មែរទេ?

សែន:	ស្រុកខ្មែរ នៅខាងនេះអស់ពីរភូមិខាងជើង នៅខាងត្បូងអស់ពាភូមិ ។

ដានី៖ អ៊ីចឹងភូមិរបស់ប្អូនលោកពូគាត់នៅវៀតណាមឈ្មោះអី?

សែន៖ ឈាង ។

ដានី៖ ដែលបានជួបគ្នាទេ?

សែន៖ ជួបទៅលេងប្អូនមកជួប ។

ដានី៖ ទៅលេងនៅណា? នៅស្រុកកំណើត?

សែន៖ បាទ!

ដានី៖ តែគាត់ចេញចូលស្រួលទេ?

សែន៖ បើគេមកយើងស្រួល បើយើងទៅគេលំបាកបន្តិច គេសួរដេញដោល អត្តសញ្ញាណបណ្ណ សួរអីទាំងអស់ បើអត់មានគេដេញមកវិញ ។

ដានី៖ គាត់ចេះខ្មែរទេ?

សែន៖ ចេះ ប្រពន្ធក៏ចេះ ។

ដានី៖ មិញ២នាក់នៅម៉ាត់ឡៃ?

សែន៖ ម្នាក់នៅម៉ាឡៃ នៅភូមិកែតមួយ នៅភូមិតាឡៅនេះមួយស្រី ។

ដានី៖ តាឡៅ នៅណា?

សែន៖ តាឡៅ នៅជាប់អណ្តូងមាស ។

ដានី៖ ហ្នឹងស្រីនៅភូមិតាឡៅ?

សែន៖ ស្រី ។

ដានី៖ ហើយលោកពូនៅនេះ?

សែន៖ ខ្ញុំនៅនេះ ។

ដានី៖ អ៊ីចឹងនៅទាំងអស់គ្នា៥នាក់?

សែន៖ ទាំងអស់ ។

ដានី៖ អ៊ំកូនទីប៉ុន្មានទៅ?

សែន៖ ខ្ញុំទី៣ ។

ដានី៖ កាលពីក្មេងៗអ៊ំរៀនសូត្រដល់ណាដែរ?

សែន៖ អត់ដែលបានរៀនផង ដឹងក្តីមកជំតិចកាលនោះធ្វើយុវ័ន្ត ធ្វើនីរសា ធ្វើអន្តរក្សក៏ទៅ តាំងពីអាយុ១៥ឆ្នាំ ទៅនៅជាមួយបងថ្លៃ។

ដានី៖ កាលហ្នឹងអាយុ១៥ឆ្នាំចូលទៅខាងណាទៅ?

សែន៖ នៅដូចថាអ្នកតស៊ូគេហ្នឹង បដិវត្តន៍គេហ្នឹង ។

ដានី: ចូលបដិវត្តន៍នៅណា?

សែន: នៅជិតភូមិហ្នឹង គ្រាន់តែនៅក្នុងព្រៃ។

ដានី: នៅជិតភូមិកែត?

សែន: បាទ!

ដានី: កាលចូលហ្នឹងចូលទៅជាមួយអ៊ំចៀម ដែលអត់ទេ?

សែន: ចូលមុនខ្ញុំទៀត។

ដានី: អ៊ំចៀម ចូលមុនអ៊ំទៀត?

សែន: បាទ!

ដានី: អ៊ំចូលឆ្នាំណាដែរ?

សែន: ខ្ញុំចូល៦៨ ចៀម ៦៦។

ដានី: អ៊ំចៀម ចូលឆ្នាំ៦៦ ហើយអ៊ំចូលឆ្នាំ៦៨។

សែន: បាទ!

ដានី: ហើយអ៊ំចូលទៅនៅជាមួយពីណា?

សែន: ខ្ញុំនៅជាមួយបងឡៅ។

ដានី: ជាមួយតាឡៅ?

សែន: បាទ!

ដានី: តាឡៅ គណៈភូមិភាគ?

សែន: បាទ!

ដានី: ធ្វើនីរសាគាត់ ឬធ្វើអីគេ?

សែន: ធ្វើនីរសារបានកន្លះឆ្នាំ គេឲ្យនៅកន្លែងមន្ទីរនីរសា។

ដានី: កន្លះឆ្នាំចេញពីកន្លែងតាឡៅ ទៅនៅមន្ទីរនីរសា?

សែន: ន-៥។

ដានី: ន-៥ ពីណាគេធ្វើប្រធានមន្ទីរនីរសា?

សែន: ស្លាប់បាត់ ដូចឆេន។

ដានី: ឆេន?

សែន: បាទ!

ដានី: កាលហ្នឹងមន្ទីរ១០០នៅណា?

សែន: មន្ទីរ១០០នៅហ្នឹងដែរ នៅស្រុក។

ដានី: នៅក្នុងភូមិអីដែរ?

សែនៈ ទេនៅក្នុងព្រៃ ។

ដានី: ក្នុងព្រៃហ្នឹងក្នុងភូមិអី?

សែនៈ ឃុំម-៤ ។

ដានី: ម ឬ ន?

សែនៈ ម ។

ដានី: ឃុំម-៤ ក្នុងស្រុក?

សែនៈ ស្រុកវ៉ឺនសៃ ។

ដានី: ស្រុកវ៉ឺនសៃវិញ មិនមែននៅក្នុងស្រុកអណ្តូងមាសទេ?

សែនៈ មិនមែនទេ ព្រោះវានៅខាងលើ ខាងក្រោមគ្នា ។

ដានី: ហ្នឹងមន្ទីរ១០០?

សែនៈ បាទ! វាជាប់គ្នាហ្នឹង ព្រំដែនស្រុកជាប់គ្នា ។

ដានី: ព្រំដែនស្រុក?

សែនៈ ស្រុកអណ្តូងមាស និងស្រុកវ៉ឺនសៃ ។

ដានី: ចុះ១០២?

សែនៈ ១០២អីទេ ។

ដានី: កាលអ៊ំចូលទៅអត់បាននៅជាមួយអ៊ំចៀម ទេ?

សែនៈ អត់ទេ អត់បាននៅរហូត បែកគ្នារហូត ជាមួយបងក៏អត់បាននៅជាមួយ បែកគ្នា ។

ដានី: អីចឹងអ៊ំទៅនៅមន្ទីរនីរសាន-៥?

សែនៈ នៅ២ឆ្នាំ ។

ដានី: នៅមន្ទីរនីរសា២ឆ្នាំ?

សែនៈ បាទ!

ដានី: ហើយយ៉ាងម៉េចទៀត?

សែនៈ បានរួចពីហ្នឹងខ្ញុំនៅស-១ នៅកន្លែងសេដ្ឋកិច្ចហើយកាន់ឃ្លាំងនោះដង ។

ដានី: នៅគ-១វិញ?

សែនៈ ស-១ ។

ដានី: ស-១ ហ្នឹងស្អីគេទៅ?

សែនៈ ស-១កន្លែងសេដ្ឋកិច្ច ។

ដានី៖ កន្លែងសេដ្ឋកិច្ចរបស់តំបន់, របស់ភូមិភាគ?

សែន៖ របស់ភូមិភាគ ។

ដានី៖ របស់ភូមិភាគអីគេ?

សែន៖ ភូមិភាគឥសាន នៅជិតអូរយ៉ាដាវ នៅភូមិគន់ឡែ ។

ដានី៖ ឆ្នាំណាមកនៅហ្នឹង? គេរដ្ឋប្រហារហើយនៅ?

សែន៖ រដ្ឋប្រហាររួចហើយ ។

ដានី៖ រដ្ឋប្រហារយូរទេបានមកនៅហ្នឹង?

សែន៖ បាទ!

ដានី៖ រដ្ឋប្រហារឆ្នាំ៧០?

សែន៖ ឆ្នាំ៧០ខ្ញុំមកអណ្ដូងមាស ខ្ញុំមកចាំមើលគេអ្នកបាតុកម្មធ្វើទាហានគេឲ្យការពារ ចាំមើលគេនៅអណ្ដូងមាសគេបាតុកម្មអណ្ដូងមាស ។

ដានី៖ ឆ្នាំ៧០មកមើលគេធ្វើបាតុកម្មហ្នឹង?

សែន៖ បាទ!

ដានី៖ ដល់ឆ្នាំចិតប៉ុន្មានបានទៅនៅស-១ មន្ទីរសេដ្ឋកិច្ចភូមិភាគ?

សែន៖ ៧២ ។

ដានី៖ នៅកន្លែងមន្ទីរសេដ្ឋកិច្ច នៅជាមួយពីណាខ្លះទៅកាលហ្នឹង?

សែន៖ នៅតាហុង ចំណាំតែតាហុង មួយទេ ។

ដានី៖ តាហុង?

សែន៖ តាហុង មួយរាងស្ដើង ។

ដានី៖ មិនមែន សូ ហុង?

សែន៖ អត់ទេ ហុង ហ្នឹងជនជាតិដែរ ។

ដានី៖ មកនៅមន្ទីរសេដ្ឋកិច្ចហ្នឹងយូរទេ?

សែន៖ នៅហ្នឹងប៉ុន្មានឆ្នាំ បានចេញពីហ្នឹងមកនៅ ១ឆ្នាំ ។ ៧៣ខ្ញុំមកនៅខាងគមនាគមន៍ដឹកជញ្ជូន ៧៣ យន្តហោះទម្លាក់ខ្លាំង ។

ដានី៖ មកនៅដឹកជញ្ជូននៅណាវិញ?

សែន៖ យកពីក្រចេះមកនៅនេះវិញ ទៅខាងរតនគិរី ទៅខាងវើនសៃ ខ្ញុំមិនមែនអ្នករត់ឡាន គេអ្នករត់តែខ្ញុំនៅក្នុងមន្ទីរហ្នឹង ។

ដានី៖ មន្ទីរគមនាគមន៍?

សែនៈ បាទ! គ្រាន់តែកត់ត្រាអីនឹងគេឯង ។

ដានីៈ មន្ទីរគមនាគមន៍របស់ភូមិភាគដែរ?

សែនៈ បាទ!

ដានីៈ ភូមិភាគឥសាន គ្នាច្រើនដែលនៅក្នុងគមនាគមន៍?

សែនៈ ច្រើនដែរ ។

ដានីៈ ដឹកទំនិញតាមម៉េច? តាមទូក, តាមឡាន?

សែនៈ តាមឡាន ។

ដានីៈ ពីក្រចេះទៅរតនគិរីដឹកតាមឡាន?

សែនៈ កាលនោះវៀតណាមនៅយើងដែរ ។

ដានីៈ មានទំនិញអីខ្លះដែលដឹកពីក្រចេះមក?

សែនៈ មានស្អី ដឹកសម្ភារៈ ។

ដានីៈ សម្ភារៈមកពីខាងណា?

សែនៈ យកពីស៊ីងត្រែង ក្រោយមកគេឈប់ហ្នឹង គេដើរទិញជាជ្រូក មាន់ យកទៅលក់ខាងវៀតណាម ឲ្យកង់ទ័ព ទាហានដូចគ្នា ដល់រួចពីហ្នឹងខ្ញុំឈប់ពីហ្នឹង ឈ្មោះភ្នំពេញ ខ្ញុំមកនៅភ្នំពេញ ។

ដានីៈ ឆ្នាំណាមកនៅភ្នំពេញ?

សែនៈ ៧៥ ។

ដានីៈ ៧៥ គេរំដោះបានភ្នំពេញ?

សែនៈ ៧៥ មកនៅភ្នំពេញបានកន្លះឆ្នាំ បានឡើងពីហ្នឹងមកនៅក្រចេះវិញ ឡើងកន្លះឆ្នាំមកនៅក្រចេះ រួចមកពីនៅក្រចេះហ្នឹងដល់៧៦ខ្ញុំទៅនៅរតនគិរីវិញនៅចំការកៅស៊ូ កម្មករនៅហ្នឹងយើងគេចប់ហើយរៀបចំ ។ ដល់៧៨គេឲ្យនៅចំការកៅស៊ូផង ចំការកប្បាសផងកាលនោះ ២ បាន១ឆ្នាំ៧៩វៀតណាមចូលស្រុកក៏បែកគ្នាមក ។

ដានីៈ អ៊ំកាលនៅភ្នំពេញធ្វើអីទៅឆ្នាំ៧៥?

សែនៈ នៅគ្រប់គ្រងខាងមន្ទីររបស់ភូមិភាគហ្នឹង កាលហ្នឹងកូនចៅគេ តែខាងគ្រប់គ្រងឲ្យគេដឹកជញ្ជូនជ័យភ័ណ្ឌចែកតាមខេត្តនៅភូមិភាគ ។

ដានីៈ យើងនៅភ្នំពេញតែសំរាប់យកឥវ៉ាន់ចែកមកខេត្ត?

សែនៈ បាទ! យកពីរដ្ឋ ពីមន្ទីររួមគេ ។

ដានីៈ កាលហ្នឹងអ៊ំមិនមែនប្រធានទេ?

សែនៈ អត់ទេ ។

ដានីៈ ពីណាគេធ្វើប្រធាន?

សែនៈ តាទុំ ។

ដានីៈ តាទុំ?

សែនៈ តាទុំ គាត់ខ្មែរដែរតែមិនដឹងគាត់នៅខេត្តណា ។

ដានីៈ គាត់ធ្វើប្រធានរហូត ឬអត់ទេ?

សែនៈ បាទ!

ដានីៈ អ៊ំអនុ?

សែនៈ ខ្ញុំកងតូចទេ គ្រាន់តែក្នុងក្រុមហ្នឹងមានគ្នា៣០នាក់ តែគាត់អត់នៅជាប់ហ្នឹងទេ ខ្ញុំនៅជាប់ហ្នឹងខ្ញុំអ្នកចាត់ចែងជំនួសគាត់ ដឹកជញ្ជូនទៅតាមភូមិភាគ ទៅខេត្តនីមួយៗ ។

ដានីៈ យើងនៅភ្នំពេញទំនាក់ទំនងជាមួយខាងណា?

សែនៈ ខាងមន្ទីររួមគេហ្នឹងហៅអីទេ ហៅគេឲ្យទៅយកទៅ គេចែកតាមភូមិភាគ យកឡានទៅដឹកសំភារៈ របស់របរផ្សេង ជ័យភ័ណ្ឌ ។

ដានីៈ គេយកឡានទៅដឹកមក?

សែនៈ បាទ!

ដានីៈ ហើយទៅនៅហ្នឹងបានតែកន្លះឆ្នាំត្រឡប់មកនៅក្រចេះវិញ?

សែនៈ បាទ!

ដានីៈ មកក្រចេះធ្វើអីទៅ?

សែនៈ នៅមិនទាន់បានធ្វើអីផង នៅបានមួយខែ ទៅនៅកន្លែងមន្ទីរពេទ្យ បានគេឲ្យទៅនៅ គ្រាន់តែស្នាក់ បានទៅនៅបាលុងវិញ ខេត្តរតនគិរី ។

ដានីៈ ត្រឡប់ទៅបាលុងគេឲ្យគ្រប់គ្រង?

សែនៈ ចំការកៅស៊ូតាមភូមិមួយៗ ហើយខ្ញុំនៅភូមិមួយនៅចំការកប្បាសហ្នឹងមួយ កាលនោះគេចាប់អ្នកចំការកប្បាសហ្នឹងមួយទៅ គេឲ្យខ្ញុំគ្រប់គ្រង២ផ្នែក ។

ដានីៈ គ្រប់គ្រងទាំងចំការកៅស៊ូផង ទាំងចំការកប្បាស?

សែនៈ បាទ!

ដានីៈ ចំការកៅស៊ូ និងចំការកប្បាសហ្នឹងរបស់ភូមិភាគ ឬរបស់អីគេ?

សែនៈ របស់ភូមិភាគ ។

ដានីៈ កាលហ្នឹងគណៈភូមិភាគពីណាគេ?

សែនៈ	តាយ៉ា ។

ដានីៈ	ពីណាទៀត?

សែនៈ	តាវង់ ។

ដានីៈ	ចុះតាឡៅ?

សែនៈ	តាឡៅ គាត់គណៈតំបន់តែគាត់ចូលក្នុងសាខាហ្នឹងឯង ។

ដានីៈ	តាឡៅ គាត់គណៈតំបន់ណាទៅ?

សែនៈ	តំបន់១០៧ ។

ដានីៈ	១០៧នៅក្នុងស្រុក ខេត្តណា?

សែនៈ	១០១ ។

ដានីៈ	ឥសានវាមានតំបន់មួយរយប៉ុន្មានខ្លះទៅ?

សែនៈ	១០១, ១០៧ តែ២ហ្នឹង ខាងក្រចេះក្តាប់មិនបានទេ ។

ដានីៈ	តំបន់១០៧ ចុះ១០២ មាន១០២អត់?

សែនៈ	មានៗ១០២ ។

ដានីៈ	នៅណាទៅ១០២?

សែនៈ	នៅរតនគិរីដែរ នៅជាប់នឹងភូមិតាតែ ។

ដានីៈ	ចុះ១០៣?

សែនៈ	១០៣ស្រុក ។

ដានីៈ	១០៤?

សែនៈ	១០៤ក៏ស្រុក ។

ដានីៈ	១០១នៅរតនគិរី ស្រុកអីខ្លះទៅតំបន់១០១?

សែនៈ	មិនដឹងទេ បើខ្ញុំមកដុតមកនេះហើយគេរៀបចំ ដល់ពេលខ្ញុំជួបគេសួរ ។

ដានីៈ	១០១នៅអណ្តូងមាស?

សែនៈ	បាទ!

ដានីៈ	អាហ្នឹងនៅអណ្តូងមាសឬមិនមែនទេ?

សែនៈ	ហ្នឹងហើយ១០១ ។ ១០២នៅជិតទៅវើុនសៃ ។ ១០៣ត្រង់ណាទេ ។

ដានីៈ	ចុះស្ទឹងត្រែងអី?

សែនៈ	វាមាននៅក្នុងខេត្តស្ទឹងត្រែង១០៤ ខ្ញុំភ្លេចដែលហ្នឹង ។

ដានីៈ	ចុះ១០៧?

សែនៈ ១០៧នៅរតនគិរី នៅជាប់នឹងភូមិគង់ឡែ ភ្លេចអស់ហើយមកប៉ុន្មានឆ្នាំ។
ដានីៈ កាលហ្នឹងគណៈតំបន់១០១ពីណាគេ?
សែនៈ មិនស្គាល់គេដែរ កាលហ្នឹងតាឡៅនៅ ស្គាល់តែតាឡៅ។
ដានីៈ តាឡៅ គាត់គណៈតំបន់ណា?
សែនៈ ១០១។
ដានីៈ ចុះ១០៧?
សែនៈ ១០៧តាធាត់ ក្រៅពីហ្នឹងអត់ស្គាល់ទេ អត់ដែលដើរទៅ។
ដានីៈ ១០២?
សែនៈ ១០២ត្រង់ណាទេ អត់ស្គាល់។
ដានីៈ ប៉ុន្តែកាលហ្នឹងអ៊ំអ្នកគ្រប់គ្រងចំការកៅស៊ូ ចំការកប្បាស យើងមានឋានៈស្មើរគណៈតំបន់ដែរ?
សែនៈ ខ្ញុំគ្រាន់តែចំការកៅស៊ូបានតែភូមិ១ តែចំការកប្បាសទាំងមូល មនុស្សជាប់ជិត១ពាន់នាក់ ៧០០-៨០០នាក់ក្នុងមួយភូមិ មួយផ្នែកៗ។
ដានីៈ អ៊ីចឹងគ្រប់គ្រង?
សែនៈ មួយភូមិ។
ដានីៈ ជិត១ពាន់នាក់ដែរ?
សែនៈ បាទ! គិតមួយសហជីព។
ដានីៈ ពេលទៅប្រជុំអ៊ំទៅប្រជុំជាមួយពីណា?
សែនៈ ប្រជុំជាមួយតាទុំ គាត់នៅមន្ទីររួម។
ដានីៈ តាទុំ នៅមន្ទីររួមនៅណា?
សែនៈ គាត់នៅបាងលុង មន្ទីររួមកន្លែងរួម។
ដានីៈ គាត់កន្លែង តាទុំ ខាងដឹកជញ្ជូននៅភ្នំពេញមុំញហ្នឹង?
សែនៈ បាទ!
ដានីៈ គាត់មកបាងលុងដែរ?
សែនៈ ដែល។
ដានីៈ មន្ទីរភូមិភាគនៅណា?
សែនៈ ភ្លេច គាត់ច្រើននៅក្រចេះនេះ។
ដានីៈ ចុះយើងគណៈចំការកប្បាស, ចំការកៅស៊ូអ៊ីចឹង មិនមែនប្រជុំជាមួយតាយា, តាវង់ ទេ?

សែនៈ	អត់ទេ តាទុំ គាត់អ្នកគ្រប់គ្រង គាត់ទៅប្រជុំ ។

ដានីៈ	កាលហ្នឹងអ៊ំអត់ដែលជួបអ៊ំចៀម ទេ?

សែនៈ	អត់ដែលជួបសោះ ទល់ផ្តាច់ខ្លួនបានជួប ។

ដានីៈ	អត់ដែលដឹងដំណឹងគាត់ទេ?

សែនៈ	អត់ កាលមកនៅនេះដឹងម្តង កាល៨២ហ្នឹងដឹងដំណឹងម្តង អត់ដែលជួបទេ ។

ដានីៈ	អ៊ំដឹងគាត់ឈ្មោះចៀម អីចឹងឬអត់ទេ?

សែនៈ	ដឹង តែនៅស្រុកពីដើមគេហៅឈ្មោះខ្ញឹង ។

ដានីៈ	ស័ន, តាចៀម ស័ន គាត់ប្រាប់ ។ ក្រោយមកគាត់ដាក់ឈ្មោះ ភី ភួន វិញ ។ អ៊ំអត់មានឈ្មោះផ្សេងទៀតទេ?

សែនៈ	អត់ ។

ដានីៈ	ឈ្មោះសែន ហ្នឹងពីដើមនៅស្រុកក៏ឈ្មោះ សែន ហ្នឹងដែរ?

សែនៈ	ពីដើមឈ្មោះបោះ ។

ដានីៈ	អ៊ំឈ្មោះបោះ?

សែនៈ	បាទ!

ដានីៈ	ដល់ពេលឈ្មោះសែន ជំនាន់ណា? ជំនាន់ចូលគស្ទូ?

សែនៈ	គស្ទូ ។

ដានីៈ	គស្ទូដាក់ឈ្មោះសែន រហូត?

សែនៈ	បាទ!

ដានីៈ	ឈ្មោះបោះ លែងប្រើឬក៏ឈប់ហើយ?

សែនៈ	ឈប់ ទៅស្រុក ខ្លះគេហៅសែន ខ្លះគេហៅបោះ ។

ដានីៈ	ចុះអ៊ំដល់ពេលយើងនៅនេះច្រើនតែខ្មែរយើងនិយាយខ្មែរ ចារ៉ាយអ៊ំអត់សូវបាននិយាយ

សែនៈ	អត់បាននិយាយផង មានប្អូនជីដូនមួយនៅនេះដែរ នៅអូរសោម ។

ដានីៈ	អូរសោម នៅខាងវាលវែង?

សែនៈ	អូរសោមទៅពីត្រពាំងប្រាសាទ ផ្លូវទៅកើត ។

ដានីៈ	បើជួបគាត់និយាយចារ៉ាយដែរ?

សែនៈ	អត់ទេ និយាយខ្មែរ ។

ដានីៈ	អ៊ំអត់និយាយយូរអីចឹងភ្លេចអស់?

សែនៈ ក្មេចខ្ទះ គេនិយាយស្តាប់បាន តែនិយាយដូចខុសៗ ទៅស្រុកគេវល់តែសើច ខ្ញុំមិនចេះភាសាគេ ។

ដានីៈ ខានយូរពេក?

សែនៈ បាទ!

ដានីៈ នៅសម័យហ្នឹងអីមានប្រសាសន៍មិញអ្នកដែលគេគ្រប់គ្រងចំការកប្បាសហ្នឹងគេចាប់ កាលហ្នឹងអីដឹងរឿងគេចាប់ដែរ?

សែនៈ ដឹងគេចាប់ គេថារឿងក្បត់ ។

ដានីៈ មានក្បត់អីចឹងមែន?

សែនៈ មិនដឹងម៉េច ។

ដានីៈ អត់ដឹង?

សែនៈ អត់ដឹង ។

ដានីៈ កាលជិនាន់ម៉េចដែរ ដូចអីអីម៉េចដែរ?

សែនៈ ពិបាកដែរ បើយើងនិយាយទៅនយោបាយមួយៗ គេអប់រំត្រូវទៅ យើងឈ្នះយើងនៅខាងនោះមើលនេះដូចខុស កាលនោះបើយើងនិយាយទៅ ខ្ញុំនិយាយត្រង់តែម្តង កាលនោះបើថាខុសតិច ខុសត្រង់ថាការសម្លាប់មិនឲ្យសម្លាប់មែន តែការសម្លាប់ថ្នាក់ណាៗគ្មានតុលាការណាកាត់ទោសត្រឹមត្រូវ សម្លាប់មានកងតូច កងធំ វរសេនាធំក៏មាន ។

ដានីៈ បានន័យថាអ៊ំចង់មានប្រសាសន៍ថា កាលហ្នឹងគេសម្លាប់យើងអត់មានតុលាការកាត់ទោសត្រឹមត្រូវទេ?

សែនៈ បាទ!

ដានីៈ ដូចថាសម្លាប់អ្នកណាមេក្រុមតូចដាងទៅសម្លាប់អនុសេនាតូច អនុសេនាធំក៏បានដែរ ។

សែនៈ បាទ!

ដានីៈ អត់មានពីណាថាអី ធ្វើអីទេ?

សែនៈ យើងវាមិនដឹង មិនសូវយល់ ។

ដានីៈ ប៉ុន្តែដូចថាអ៊ំ ក្រុមគ្រួសារអ៊ំ មិត្តភក្តិអត់អីទេ?

សែនៈ អត់អីទេ ព្រោះកាលនោះ កាលខ្ញុំរៀន ខ្ញុំធ្លាប់រៀនដែរ គេថាយើងមិនមែនសម្លាប់ប្រជាជនទេ យើងចង់ជំរុះរបបត្រង់មនុស្សគេថាមិនសម្លាប់ទេ បានន័យដល់ពេលអីចឹងទៅវាលំបាកដែរ ។ អីចឹងដល់ក្រោយមកគេថាយើងចាប់គេមួយ គេចាប់យើងពីរ យើងចាប់គេ៤-៥ គេចាប់១០-២០ វាទៅមកៗអីចឹង មិនដឹងអ្នកណាខុស អ្នកណាត្រូវ

ខ្ញុំមិនយល់ដែរ វាមានខ្មាំង យើងចាប់ខ្មាំង១ ខ្មាំងចាប់យើង៤-១០ ។ ដល់អីចឹងមិនដឹងខាងណាត្រូវ ខាងណាខុសវាមិនយល់ដែរ ។

ដានី: កាលហ្នឹងអ៊ីមានគ្រួសារតាំងពីឆ្នាំណាមក?

សែនៈ ខ្ញុំមានតាំងពី៩១ ខ្ញុំយកនៅកំពង់ចាម ។

ដានី: ទើបតែឆ្នាំ៩១នេះទេ?

សែនៈ បាទ!

ដានី: តាំងពីមុនមកអត់ដែលមានទេ?

សែនៈ មុនយកបានដល់យួនចូលស្រុកក៏បែកគ្នា គេយកប្តីទៅ ខ្ញុំនៅតែលៗ ។

ដានី: នៅណា?

សែនៈ នៅស្ទឹងត្រែង ។

ដានី: យកតាំងពីឆ្នាំណាហ្នឹង?

សែនៈ តាំងពី៧៧-៧៨ ។

ដានី: គាត់អ្នកស្ទឹងត្រែង?

សែនៈ បាទ!

ដានី: មានកូនអត់ជាមួយគាត់?

សែនៈ កូនមួយស្លាប់ ។

ដានី: ដល់ពេលយួនចូលទៅបែកគ្នា?

សែនៈ បែកគ្នា ។

ដានី: បែកគ្នានៅណា?

សែនៈ ស្ទឹងត្រែង ។

ដានី: ហើយគេនៅស្ទឹងត្រែងទៅ?

សែនៈ គេនៅស្ទឹងត្រែង នៅភូមិគេនៅហ្នឹង នៅភូមិខ្វាវ ។

ដានី: អ៊ំអត់ទៅនៅភូមិគេ?

សែនៈ អត់គេរៀបចំឲ្យទៅទុកតាមផ្លូវហ្នឹងគេចូលមក ខ្ញុំទៅទុកនៅស្រែពកគ្នាប៉ុន្មាននាក់ ៣០០នាក់ ដល់ពេលវៃដាច់ក៏ខ្ញុំនៅចុងគេនោះ មិនដឹងគេរត់ចោល ដល់នេះយួនចូលពេញបំបែកគ្នាខ្ញុំឆ្លងមកព្រំដែនឡាវ មកនៅព្រំដែនឡាវ ។

ដានី: អីចឹងអ៊ំពេលបែកឆ្នាំ៧៩ ពេលយួនចូលអ៊ំចូលធ្វើទាហានវិញហើយ?

សែនៈ បាទ!

ដានី៖ ធ្វើទាហានមុនយួនចូលទៀត ឬយ៉ាងម៉េច?

សែន៖ ចូលពេលគេចូលមកដល់ រត់មកដល់ស្ទឹងត្រែងបានគេប្រគល់កាំភ្លើង គេហៅទៅគេប្រគល់កាំភ្លើងឲ្យបណ្តោយ ។

ដានី៖ គេឲ្យទៅមកទប់នៅណា?

សែន៖ នៅទន្លេស្រែពក ។

ដានី៖ ហ្នឹងអត់ទាន់មាននៅក្នុងកងពល អន្តភាពអីទេ?

សែន៖ នៅទេ ទៅចំរុះតែម្តង គេប្រមូលដាក់ៗ ។

ដានី៖ គ្នា៣០០នាក់ដែរមកទន្លេស្រែពក?

សែន៖ បាទ! ចំរុះក្នុងចំការកៅស៊ូ មកតាមភូមិគេហ្នឹងផង ភូមិគេមួយៗតាមផ្លូវ ។

ដានី៖ តែអ៊ំអ្នកដឹកនាំ៣០០នាក់ហ្នឹង?

សែន៖ ទេ គេអ្នកដឹកនាំ ខ្ញុំគេប្រមូលអីចឹងទៅធម្មតានឹងគេឯង គេមិនរៀបចំពីណាដឹកនាំពីណាផងចេះតែទៅ ។

ដានី៖ ទៅនៅហ្នឹងយូរអត់ទប់ទល់ហ្នឹង ។

សែន៖ មួយថ្ងៃមួយយប់ ។

ដានី៖ ចុះប្រពន្ធនៅណាពេលហ្នឹង ដល់ពេលយើងមកទប់ទល់?

សែន៖ នៅស្ទឹងត្រែង ។

ដានី៖ ប្រពន្ធនៅស្ទឹងត្រែងយើងទេ? អត់ទៅនៅជាមួយរតនគិរី?

សែន៖ រត់ពីនោះទាំងអស់គ្នា រត់ពីបាងលុង ខេត្តរតនគិរីមកចូលស្ទឹងត្រែង ។

ដានី៖ ដល់ពេលរត់មកទាំងអស់គ្នាមកចូលស្ទឹងត្រែង?

សែន៖ បាទ!

ដានី៖ ដល់ពេលចូលស្ទឹងត្រែងហើយបានអ៊ំទៅស្រែពកទៀត?

សែន៖ បាទ! គេឲ្យបកទៅនោះវិញ ។

ដានី៖ អីចឹងអ៊ំពេលមកដល់ស្ទឹងត្រែង ពេលដែលអ៊ំកាន់កាំភ្លើងទៅទប់នៅស្រែពក ប្រពន្ធអត់ទៅទេ ប្រពន្ធនៅស្ទឹងត្រែងដដែល?

សែន៖ អត់ទៅទេ អត់មានពីណាឲ្យទៅទេ ទៅតែប្រុសៗ ។

ដានី៖ បែកគ្នាតាំងពីហ្នឹង?

សែន៖ បែកពីហ្នឹងមករហូត ចូលមកមិនដឹងគេទៅខាងណា អត់ដឹង ។

ដានី៖ ដល់ពេលអ៊ំទៅទប់នៅស្រែពកតែមួយថ្ងៃ មួយយប់ទេ?

សែនៈ បាទ!

ដានីៈ ហើយមួយថ្ងៃ មួយយប់ អត់ត្រឡប់មករកប្រពន្ធវិញទេ?

សែនៈ មកហ្នឹង គេចូលពេញ ។

ដានីៈ យួនចូលពេញ?

សែនៈ យួនចូលពេញ ។

ដានីៈ ដល់ពេលយួនចូលពេញអ៊ំត្រឡប់ទៅខាងណាវិញ?

សែនៈ ខ្ញុំឆ្លងទៅដីឡាវ ។

ដានីៈ ជិះអីឆ្លងទៅ?

សែនៈ ដី៣០គីឡូ ។

ដានីៈ ឆ្លងទន្លេមេគង្គ?

សែនៈ ឆ្លង ឆ្លងទូកតាមភូមិហ្នឹង ឆ្លងទៅ ។

ដានីៈ គ្នា៣០០នាក់ហ្នឹងឆ្លងមក?

សែនៈ គ្នា៣០នាក់ ក្រៅពីហ្នឹងមិនដឹងគេទៅណាអស់ ខ្លះក៏ទៅតាមភូមិ ខ្លះទៅតាមប្រពន្ធគេ ។

ដានីៈ ហើយអ៊ំឆ្លងទូកមកគ្នាតែ៣០នាក់ទេ?

សែនៈ បាទ!

ដានីៈ ឆ្លងពីត្រង់ណាហ្នឹង?

សែនៈ ក្លួចឈ្មោះបាត់ ខាងលើស៊ឹងត្រែង ។

ដានីៈ ហើយឆ្លងមកខាង?

សែនៈ ឆ្លងមកជើង ។

ដានីៈ ឆ្លងមកចំកន្លែងណាទៅ?

សែនៈ ឆ្លងនៅជុំក្រឡូ ។

ដានីៈ ព្រំដែនតែម្តង?

សែនៈ ព្រំដែន ។

ដានីៈ ហើយឆ្លងមកធ្វើអីទៀតទៅ?

សែនៈ ឆ្លងមកនៅហ្នឹង កាលហ្នឹងចូលអង្គភាពជាមួយគេទៅ គេប្រមូលទៅចូលនៅ១០១ អង្គភាពគេ ។

ដានីៈ អង្គភាពស្អីគេ១០១?

សែនៈ ១០២ មិនមែន១០១ទេ ទាហានកងទ័ព ។

ដានី៖ កងទ័ព១០២?

សែន៖ បាទ!

ដានី៖ កងពលឬស្ពីគេ១០២ហ្នឹង?

សែន៖ វរសេនាធំ ។

ដានី៖ វរសេនាធំ១០២?

សែន៖ បាទ!

ដានី៖ ពីណាគេធ្វើប្រធាន?

សែន៖ តាឡេ នៅក្នុងវរសេនាធំ ។

ដានី៖ តាឡេ គាត់ជនជាតិដែរ?

សែន៖ តាឡេ ជនជាតិ ។

ដានី៖ មិនមែនក្នុងតំបន់១០២ទេ?

សែន៖ អត់ទេ ។

ដានី៖ វរសេនាធំ១០២?

សែន៖ គេដាក់៦១, ៦២ តែអនុសេនាធំ១១ ។

ដានី៖ អនុសេនាធំ១១ ។

សែន៖ ហ្នឹងអនុសេនាធំ១១ ។

ដានី៖ ចុះវរសេនាធំ?

សែន៖ វរសេនាធំ២ ។

ដានី៖ កងពលលេខប៉ុន្មាន?

សែន៖ ៨០១ ។

ដានី៖ ពីណាគេប្រធានកងពល?

សែន៖ តា០៥ ។

ដានី៖ អនុតា០៥ ពីណាគេ?

សែន៖ តាអីនៅនេះ នៅជិតតារ៉ែន ។

ដានី៖ អ៊ុន រ៉ែន ហ្នឹង?

សែន៖ ហ្នឹងហើយបងរ៉ែន, តាធិន ហើយតា០៥ ហើយពីណាមួយទៀត ។

ដានី៖ តារ៉ែន, តាធិន ពេលដែលយើងរត់ហ្នឹង?

សែន៖ បាទ!

ដានី: អីចឹងវរសេនាធំ១០១តាឡេ ធ្វើប្រធាន?

សែន: បាទ!

ដានី: ហើយមកដល់ជុំក្រឡូចូលក្នុងកងគេហើយយ៉ាងម៉េចទៀត?

សែន: នៅហ្នឹងបានប៉ុន្មាន ជិតមួយឆ្នាំ នៅដូចថានៅពួន គេដើរធ្វើការ ប្រជាជនដើរជួប ធ្វើនយោបាយការតស៊ូអីម៉េចៗ អ្នកណាខុស អ្នកណាត្រូវ អ្នកណាឈ្នះពាន ណែនាំនៅកន្លះឆ្នាំ បានឡើងមកថៃហ្នឹង ។

ដានី: កន្លះឆ្នាំ?

សែន: បាទ!

ដានី: ឆ្នាំណាបានឡើងមកដល់? ឡើងមកថៃ?

សែន: ៨១ ។

ដានី: ឡើងមកថៃ ឡើងមកម្តុំណា?

សែន: នៅម៉ុំ៣ ។

ដានី: ឆ្នាំ៨១ឡើងមកម៉ុំ៣ ឡើងជងវែក?

សែន: បាទ! ឡើងជងវែក ។

ដានី: ឡើងម៉ុំ៣ កាលហ្នឹងគេហៅអីគេម៉ុំ៣?

សែន: កាលនោះហៅ១០០១កន្លែង ។

ដានី: ពីណាគេអ្នកគ្រប់គ្រងនៅ១០០១?

សែន: គេហៅ១០០១, ១០០២ តែ១០០១តាម៉ុក គេនៅគ្រប់គ្រងរហូត នៅហ្នឹងចំរុះច្រើនណាស់ ។

ដានី: ឡើងមក១០០១យ៉ាងម៉េច ឡើងមកកងពល៨០១ ឡើងមកទាំងអស់?

សែន: មកមួយចំនួន មកតៗគ្នា ខ្ញុំមកគ្នា៧០នាក់ នៅដីឡាវនោះមួយខែ ។

ដានី: ដល់ពេលឡើងមក១០០១មកធ្វើអី?

សែន: មិនទាន់បានធ្វើការងារអីទេ នៅគេបំប៉នសិនទំនេរ បានមួយខែបានគេរៀបចំនៅតាមអង្គភាព ធ្វើការចុះមកក្រោមៗ ដើរធ្វើការប្រជាជនតាមភូមិមួយៗធ្វើតែប៉ុណ្ណឹង កំលាំងគេអ្នកវៃគេវៃទៅ គ្រប់គ្រងប្រជាជនតាមព្រំដែន រួចពីហ្នឹងមកនៅពើយព្រេច មកពី១០០១ ។

ដានី: ពើយព្រេចនៅណា?

សែន: ពើយព្រេចនៅខាងកើតព្រះវិហារ ប្រាសាទព្រះវិហារ ភ្នំខ្ពស់ជាងគេហ្នឹង ។

ដានីៈ តែនៅ១០០១ កាលហ្នឹងប៉ុន្មានកងពលឡើងមកនៅ១០០១?

សែនៈ ១០០១ ។

ដានីៈ មានកងពលណាខ្លះ?

សែនៈ ៨០១ ភ្លេច កងពលណាក៏ឡើងតាមហ្នឹងដែរកាលនោះ ៩២០គេឡើងតាមហ្នឹង ។

ដានីៈ ហើយកងពលណាទៀត? កងពលរបស់ខាងណា? មេកងពលឈ្មោះអីគេ?

សែនៈ ក្តាប់វាមិនបានដែរបេះតែឡើង មិនដឹងកងពលណាខ្លះ គេរុញបេះតែរុញមក ក្តាប់មិនបាន

ដានីៈ អីចឹងអ៊ំនៅ១០០១បានរយៈពេលប៉ុន្មានបានគេរុញឲ្យមកនៅ?

សែនៈ ជិតកន្លះឆ្នាំ ។

ដានីៈ ជិតកន្លះឆ្នាំបានគេឲ្យមកនៅ?

សែនៈ ពើយព្រេច ។

ដានីៈ ក្នុងឆ្នាំ៨១ដដែល?

សែនៈ បាទ!

ដានីៈ មកធ្វើអីនៅកន្លែងហ្នឹង?

សែនៈ ធ្វើការប្រជាជន គេឲ្យដើរវ៉ៃតែខ្ញុំ បងទីៗ គាត់នៅអនុសេនាធំ កាលនោះខ្ញុំនៅយុទ្ធជន គាត់អត់ឲ្យខ្ញុំដើរទេ គាត់រៀបចំទៅគេដើរ ខ្ញុំនៅចាំកន្លែង ។

ដានីៈ ចាំកន្លែងនៅ?

សែនៈ លើភ្នំ ។

ដានីៈ លើភ្នំពើយព្រេចហ្នឹង?

សែនៈ បាទ! ក្រៅពីហ្នឹងគេចុះធ្វើការក្រោម ។

ដានីៈ ស្រុកអីគេ?

សែនៈ ស្រុកដាំក្សាន្ត ដល់រួចមកបានខ្ញុំមកនៅត្រង់នេះ នៅដូវដាន ។

ដានីៈ ដូវដាននៅណា?

សែនៈ ខាងលិចពើយព្រេច បង្គោល៨ជាប់ មកហួសមកនេះនៅបង្គោល៨ ។

ដានីៈ ពើយ៨?

សែនៈ បង្គោល៨ ។

ដានីៈ កាលនៅពើយព្រេច អ៊ំនៅមន្ទីរនៅមន្ទីររបស់ស្អី? មន្ទីររបស់កងពល ឬមន្ទីររបស់វរៈ?

សែនៈ អនុសេនាធំ ។

ដានីៈ មន្ទីរអនុសេនាធំទេ?

សែនៈ បាទ!

ដានីៈ មកពើយព្រេចហ្នឹងតែមួយអនុសេនាធំទេអ៊ីចឹង?

សែនៈ បាទ!

ដានីៈ តែកងពលនៅ៨០១ដដែល?

សែនៈ នៅ៦២ កងពល៦២ ។

ដានីៈ ៦២នៅណា?

សែនៈ តាហឿន ។

ដានីៈ ៩១២?

សែនៈ អត់ទេ ៦២ ។

ដានីៈ អ៊ីចឹងអ៊ំមកពើយព្រេចមកក្នុងកងពលតាហឿន វិញហើយ?

សែនៈ បាទ! របស់តាហឿន ។

ដានីៈ ឈប់នៅ៨០១ហើយ?

សែនៈ ឈប់ហើយ ។

ដានីៈ ម៉េចបានអ៊ីចឹង?

សែនៈ គេបែកកំលាំង តាហឿន ប្រធាន តាឈាន អនុ ។

ដានីៈ តាហឿន ប្រធាន, តាឈាន អនុ?

សែនៈ តាឈាន ប្រធាន, តាហឿន អនុ យោធានយោបាយ ខ្ញុំនៅជាមួយវរសេនាធំតាអ៊ុន នៅកាំភ្លើងធំ ។

ដានីៈ មកនៅព្រះវិហារហ្នឹងកងពលរបស់តាហឿន ទេ?

សែនៈ បាទ!

ដានីៈ មិនមែនកងពល៨០១ទេ?

សែនៈ អត់ទេ ។

ដានីៈ ចុះអ៊ំមានបាននៅលើប្រាសាទព្រះវិហារដែលអត់?

សែនៈ ខ្ញុំទៅកាលខ្ញុំទៅពីក្មេង ទៅវ៉ៃឡើងទៅនៅហ្នឹង ។

ដានីៈ ឆ្នាំណា?

សែនៈ កៅប៉ុន្មានទេ កាលហ្នឹងវ៉ៃដាច់អស់ហើយ ។

ដានីៈ វ៉ៃដាច់អស់ហើយបានយើងឡើងទៅនៅប្រាសាទ ។

សែនៈ ហ្នឹងហើយ ។

ដានី: កាលពីមុនមកយើងអត់អាចនៅលើប្រាសាទទេ កាលអ៊ំនៅពើយព្រេច?

សែន: នៅទេកាលនោះ ។

ដានី: កាលហ្នឹងពីណានៅលើប្រាសាទ?

សែន: កាលនោះខាងក្នុង ។

ដានី: អីចឹងខ្មែរក្រហមយើងអត់ទេ?

សែន: អត់ទេ ។

ដានី: តាំងពី៧៩មកអត់បាន?

សែន: បាទ!

ដានី: ទៅនៅពើយព្រេចមកនៅបន្ទោល៨ហ្នឹងឆ្នាំណា?

សែន: បន្ទោល៨ ខ្ញុំនៅកាំភ្លើងធំ មិនបានវ៉ៃតប់នឹងគេទេ ថាមិនវ៉ៃដូចវ៉ៃដែរ នៅកាំភ្លើងធំ ។

ដានី: នៅខាងក្រុមកាំភ្លើងធំ?

សែន: បាទ!

ដានី: នៅជាមួយតាអ៊ីម?

សែន: បាទ!

ដានី: នៅបន្ទោល៨យូរទេ?

សែន: យូរដែរ ។

ដានី: បន្ទោល៨ ជិតប្រាសាទព្រះវិហារដែរ?

សែន: ជិត ប៉ាំងតែភ្នំចាបមួយ ។

ដានី: ស្រុកជាំក្សាន្តដដែល?

សែន: ស្រុកជាំក្សាន្ត ។

ដានី: នៅយូរអត់នៅបន្ទោល៨ហ្នឹងដល់ពេលណាទៅ?

សែន: ដល់៨៦បានយើងចុះទៅក្នុង ។ ៨៦ខ្ញុំទៅជួយវ៉ៃថៃ យួនវាទៅ យកដីថៃ៨៦ បានខាងក្នុងបុកទៅ ។

ដានី: អីចឹង៨៦យួនវ៉ៃចូលទៅថៃទៀត?

សែន: យកកូនភ្នំមួយ វ៉ៃនៅដីថៃ ។

ដានី: យួន?

សែន: បាទ!

ដានី: យួនចូលដល់ដីថៃ?

សែនៈ បាទ!

ដានីៈ នៅកន្លែងណាហ្នឹង?

សែនៈ ភ្នំបុស្សលិច គេហៅភ្នំបុស្ស ។

ដានីៈ ជួយអីថៃ? ថៃអីអត់ឈ្នះយួនទេ?

សែនៈ អត់ បានហៅពួកខ្ញុំទៅគ្នា១០០នាក់ទៅ អីមួយថ្ងៃដាច់ ។

ដានីៈ នៅណាទៅកាលហ្នឹង? ភ្នំបុស្សនៅណា?

សែនៈ ភ្នំបុស្សនៅលិចខេត្តសារិន ។

ដានីៈ ក្នុងខេត្តសារិន?

សែនៈ តែថៃវាហៅភូបុស្ស។ តែខ្ញុំហៅភ្នំបុស្ស ថៃហៅភូបុស្ស ចេះតែហៅតាមភាសាវា ។

ដានីៈ ភូហ្នឹងភ្នំ?

សែនៈ បាទ!

ដានីៈ ភ្នំហ្នឹងនៅក្នុងខេត្តសារិន? នៅស្រុកអីយើង? នៅទល់មុខស្រុកអីយើង?

សែនៈ អត់ដឹងដែលកាលហ្នឹង ។

ដានីៈ សារិននៅខាងណាជិតអន្លង់វែង?

សែនៈ ខាងលិចអន្លង់វែង ។

ដានីៈ ខាងលិចអន្លង់វែងខាងណាចេះ? ខាងអូរអង្រែ, ត្រពាំងតាវ ឬហួសហ្នឹងទៀត កន្លែងប្រក៨០៨?

សែនៈ បាទ! យើងចុះពីនេះមិនស្គាល់ មិនដឹងទៅណា ខ្ញុំជិះឡានជូវក្នុងនេះ ដីថៃ ។

ដានីៈ អីចឹងឆ្នាំ៨៦ទៅជួយអី ទៅអីរយៈពេលប៉ុន្មានអីបាន?

សែនៈ បានមួយថ្ងៃ អីម៉ោង៧ ដល់ម៉ោង២ដាច់ ។

ដានីៈ ថៃជួយដែរ?

សែនៈ ជួយ ជួរកាំភ្លើងធំជាមួយគ្នា ។

ដានីៈ យួនគ្នាតិចឬយ៉ាំងម៉េចបានយើងអីដាច់?

សែនៈ យួនគ្នាច្រើនដែរ បន្ទាយវាធំដែរ ។

ដានីៈ វាដកចេញវិញ?

សែនៈ វាទ្រាំមិនបាន នៅភ្នំតូចមួយហ្នឹង ។

ដានីៈ គេព័ទ្ធវា?

សែនៈ	កាំភ្លើងធំព័ទ្ធជុំវិញ ទៅចូលវៃរបួសមួយបន្ទុយហើយទៅជ្រុំមួយសារទៀតទាំងថៃ ទាំងយើង បុកមួយសារទៀតដាច់ ។

ដានីៈ	វារត់ចេញ ឬស្លាប់អស់?

សែនៈ	រត់ចុះក្រោមមកដីខ្មែរយើង ។

ដានីៈ	ដាច់ហើយយើងទៅណា?

សែនៈ	ដាច់ហើយមកវិញ ។

ដានីៈ	មកខាងណាវិញ?

សែនៈ	មកស៊ឹងចាន់ ជិះឡានពីម៉ោង៣ដល់ម៉ោង៧បានដល់នេះ ម៉ោង៣ល្ងាចដល់ម៉ោង៧ជិតភ្លឺមកដល់នេះ ។

ដានីៈ	មកដល់ស៊ឹងចាន់វិញ?

សែនៈ	បាទ!

ដានីៈ	ហើយយ៉ាងម៉េចទៀតមកស៊ឹងចាន់?

សែនៈ	មកស៊ឹងចាន់ដល់ក្រោយគេរៀបចំខ្ញុំចុះទៅធ្វើការកំពង់ចាម ។

ដានីៈ	ឆ្នាំណាដែលចុះទៅធ្វើការកំពង់ចាម?

សែនៈ	៨៦ហ្នឹងឯង ចុង៨៦ ។

ដានីៈ	នៅក្នុងកងពលតាហឿនដដែល?

សែនៈ	បាទ!

ដានីៈ	កងពលតាហឿន ទៅធ្វើការដល់កំពង់ចាមដែរ?

សែនៈ	គេចែកតាមវរសេនាធំ គេយកវរសេនាធំមួយៗតាមកងពលចុះទៅក្នុង ។

ដានីៈ	ចុះអ៊ំក្នុងវរសេនាធំរបស់តាអ៊ុម ដដែល?

សែនៈ	តាអ៊ុម គេទៅខាងតាស័ន ។

ដានីៈ	តាស័ន ក្រុមប្រឹក្សានេះ?

សែនៈ	បាទ!

ដានីៈ	តាស័ន គាត់ប្រធានវរៈ?

សែនៈ	បាទ!

ដានីៈ	ប្រធានវរសេនាធំ?

សែនៈ	វរសេនាធំ អស់ពីតាអ៊ុម ទៅគឺគាត់ ។

ដានីៈ	គាត់ធ្វើប្រធានវរសេនាធំហើយគាត់ទៅវៃនៅណាទៅ?

សែនៈ គាត់នៅលើហ្នឹង ដល់ខ្ញុំដាច់ពីគាត់ទៅ ក៏ទៅជាមួយតាស៊ុន វរសេនាធំជាមួយគ្នាប្រធានភូមិ ជាមួយខ្ញុំ គេនយោបាយ ខ្ញុំយោធា វរសេនាតូចដូចគ្នា ។

ដានីៈ ដល់ពេលនេះអ៊ំឡើងបានវរសេនាតូច?

សែនៈ បាទ!

ដានីៈ វរសេនាតូចទៅវ៉ៃកំពង់ចាមនៅស្រុកណា?

សែនៈ នៅត្បូងឃ្មុំ ។

ដានីៈ ចូលទៅដល់ឆ្លងទន្លេទៅទៀត?

សែនៈ ឆ្លង ។

ដានីៈ យើងឆ្លងតាមណា?

សែនៈ ឆ្លងតាមភូមិ ។

ដានីៈ ឆ្លងយើងត្រៀមពីខាងលិច ទៅកើតតាមណា?

សែនៈ ឆ្លងពីដីនឹក ។

ដានីៈ កាលហ្នឹងទាហានកង៍ទ័ពគេអត់ឃើញយួនអី?

សែនៈ តែយួនអត់នៅទេ មានអីគេទាក់ទងទៅមុន គេឲ្យឆ្លង មានផ្ទៃក្នុង ។

ដានីៈ ឆ្លងយប់ឬថ្ងៃ?

សែនៈ យប់ ឆ្លងមួយយប់ទល់ភ្លឺ ដល់ឆ្លងផុតគេបាញ់តាមក្រោយ ។

ដានីៈ ឆ្លងទៅគ្នាច្រើន?

សែនៈ ជួនកាល៣០០-៤០០នាក់, ២០០នាក់ ។

ដានីៈ កាំភ្លើងស្លាយទៅដែរ?

សែនៈ ស្លាយទៅទាំងអស់ ។

ដានីៈ ចុះបើបាញ់អស់គ្រាប់ធ្វើម៉េច?

សែនៈ មិនអីទេ អត់សំខាន់រឿងវ៉ៃទេ សំខាន់នយោបាយ ។

ដានីៈ ទៅធ្វើនយោបាយ?

សែនៈ កន្លែងទល់ច្រកបានវ៉ៃ បើជាក្រុមគេវ៉ៃផ្សេង ខ្ញុំទៅដល់បឹងពិត ។

ដានីៈ ទៅធ្វើនយោបាយយ៉ាងម៉េចខ្លះទៅ?

សែនៈ ណែនាំអំពីនយោបាយនីមួយៗគេដឹកនាំអីដើម្បីអី ផលប្រយោជន៍អ្នកណា ។

ដានីៈ អ៊ីចឹងចុះទៅខាងកំពង់ចាមមិនមែនមួយវរសេនាធំតាស៊ន ទៅទាំងអស់ទេ?

សែនៈ អត់ទេ ។

ដានី: វរសេនាធំលេខប៉ុន្មានហ្នឹង?

សែន: វរសេនាធំ៦២ ។

ដានី: អីចឹងក្នុងកងពលរបស់តាហឿន មានវរសេនាធំ៦២, ហុកប៉ុន្មានខ្លះ?

សែន: ៦១, ៦២ ។ ២វរសេនាធំ ។

ដានី: អត់មាន៦៣ទេ?

សែន: ៦៣មួយ ៦៣គេទៅកោះកុង ។

ដានី: ៦៣ទៅខាងកោះកុងវិញ?

សែន: បាទ! តាឆន ទៅ ។

ដានី: វរសេនាធំ៦៣ឈ្មោះអីទេ?

សែន: តាឆន ។

ដានី: ដល់ពេល៦១?

សែន: ៦១តា០៦ ។

ដានី: មិនមែនតាសាន ០៦ទេ?

សែន: តាសាន ហ្នឹងឯង ។

ដានី: តាសាន កងពលជាមួយតា ។

សែន: វរសេនាធំ?

ដានី: បាទ! ខ្ញុំចង់ដឹង៦១របស់?

សែន: ភ្លេចបាត់ហើយ ភ្លេចឈ្មោះគេ តាអីទេទៅស្រុក ជាប់គុកអន្លង់វែង ។

ដានី: ឈ្មោះតាអី?

សែន: ជាប់គុកជាមួយតា០៥ ។

ដានី: តែគាត់អត់ស្លាប់ទេ?

សែន: ភ្លេចឈ្មោះគាត់ ។

ដានី: អីចឹងអ៊ំទៅខាងកំពង់ចាមបានយូរទេ?

សែន: យូរ ទៅតាំងពី៨៦ហ្នឹងរហូតទល់យើងផ្ដាច់ខ្លួនបានមកវិញ កៅប៉ុន្មាន ។

ដានី: កៅប៉ុន្មាន?

សែន: ៩៦ កាលនោះផ្ដាច់ខ្លួន ។

ដានី: កាលអ៊ំគេហៅមកវិញហ្នឹង តាម៉ុក ហើយប៉ុល ពត ឈ្លោះគ្នានៅ?

សែន: គេហៅមកដល់ហើយបានឈ្លោះគ្នា ។

ដានី: មកមុនគេឈ្មោះគ្នា?

សែន: បាទ!

ដានី: មកមុនគេចាប់តា០៥, ០៦, តាសុន សេន គេសម្លាប់អ៊ីមកដល់នៅ?

សែន: ហ្នឹង ខ្ញុំមកដល់។

ដានី: មកមុនយូរទេ បានគេនេះ?

សែន: មកបានកន្លះខែ ដល់អីចឹងគេប្រមូលទៅដីថៃ។

ដានី: តាម៉ុក ចង់ប្រមូលទៅទៀត?

សែន: ប្រមូលទៅទប់ទល់គ្នា មិនបានទៅនឹងគេផង នាំគ្នានៅហ្នឹង គេរៀបចំហើយបានគេហៅតា ០៦, ០៥។ តា០៥ គាត់ជួបខ្ញុំ ថាបងទៅណា ថាមិត្តអើយឆាកនយោបាយកុំទៅចូលប្រឡូកឲ្យសោះ ឈប់ទៅ គាត់ផ្តាំតែប៉ុណ្ណឹង។

ដានី: ម៉េចបានគាត់អីចឹង?

សែន: មិនដឹងថាម៉េច ឆាកនយោបាយកុំប្រឡូកឲ្យសោះ ខាងណាឈ្នះទៅខាងហ្នឹង ខាងណាច្រើនទៅហ្នឹង គាត់ថាតែប៉ុណ្ណឹង។

ដានី: គាត់ទៅណា?

សែន: គេហៅគាត់ទៅអន្លង់វែង តាម៉ុក ហៅគាត់ទៅចាប់គាត់។

ដានី: គាត់ជិះអីទៅ?

សែន: ដើរ។

ដានី: គាត់ដើរទៅ?

សែន: បាទ!

ដានី: ដើរពីណាទៅ?

សែន: ដើរពីនេះអូរស្វាយ។

ដានី: កាលហ្នឹងអត់មានអីជិះ?

សែន: អត់ទេ។

ដានី: ហើយអ៊ីថាអ៊ីការជាមួយគ្រួសារអ៊ីក្រោយទៀតឆ្នាំណា?

សែន: ឆ្នាំ៩១។

ដានី: ៩១ពេលអ៊ីនៅណា?

សែន: នៅការក្នុងព្រៃ នៅភូមិធាង។

ដានី: ភូមិអីគេ?

សែនៈ ភូមិឃាង ។

ដានីៈ ឃាង?

សែនៈ បាទ!

ដានីៈ ភូមិឃាងនៅណា?

សែនៈ ជិតជីនឹក ។

ដានីៈ ភូមិហ្នឹងនៅជិតព្រៃ?

សែនៈ នៅនឹងព្រៃ នៅបឹងតាឃាង តែនៅខេត្តក្រចេះ ។

ដានីៈ ស្រុកអីគេនៅហ្នឹង? ស្រុកស្នួល ឬស្រុកឆ្លូង?

សែនៈ ស្រុកក្រូចឆ្មារ ។

ដានីៈ ស្រុកក្រូចឆ្មារខេត្តកំពង់ចាម?

សែនៈ បាទ!

ដានីៈ ព្រៃនុយអីហ្នឹង?

សែនៈ ហ្នឹងហើយ ព្រៃនុយ ។

ដានីៈ អ៊ំស្គាល់ព្រៃនុយហ្នឹងដែរ?

សែនៈ នៅប៉ុន្មានឆ្នាំ នៅរហូតហ្នឹង ។

ដានីៈ នៅក្នុងព្រៃនុយហ្នឹងតែម្តង?

សែនៈ បាទ! នៅហ្នឹងធ្វើចំការ ។

ដានីៈ នៅធ្វើចំការដែរ?

សែនៈ បាទ! នៅភូមិឃាង ។

ដានីៈ ក៏ការឆ្នាំ៩១ទៅ?

សែនៈ បាទ!

ដានីៈ កាលហ្នឹងអ៊ំអាយុប៉ុន្មានហើយការ?

សែនៈ សែជាងហើយ ។

ដានីៈ ៩១ការ ការបានប៉ុន្មានឆ្នាំបានឡើងមកលើភ្នំគេហៅមក?

សែនៈ យូរដែរ ។

ដានីៈ បានកូននៅកាលហ្នឹង?

សែនៈ បានកូន២ មួយឆ្នាំមួយ ។

ដានីៈ បាន២បានឡើងមក?

សែនៈ បាទ!

ដានីៈ ដល់ពេលឡើងមកគេនេះបណ្ដោយ?

សែនៈ គេឈ្លោះគ្នា ។

ដានីៈ ពេលមុនឡើងមក ពេលចុះមកនៅនេះដំឡូងអីអត់បានចុះមកនៅនឹងគេទេ?

សែនៈ នៅទេ ខ្ញុំអត់ដឹងទេគេចុះមកនៅនេះ ខ្ញុំនៅនោះរហូត ខ្ញុំថាមកគេមិនឲ្យមក ធ្វើការនោះរហូត ។

ដានីៈ ពីណាអត់ឲ្យមក?

សែនៈ មេៗ ។

ដានីៈ មេខាងលើ?

សែនៈ ថាមិនបាច់មកទេប្រពន្ធនៅនោះហើយ ។

ដានីៈ ពេលហ្នឹងអ៊ំនៅកងពលជាមួយតា?

សែនៈ កាលនោះនៅវរសេនាធំឯករាជ្យ គេផ្ដាច់ពីកងពលហើយ ។

ដានីៈ ពេលនៅកំពង់ចាម វរសេនាធំឯករាជ្យ?

សែនៈ ជាមួយតាស៊ុនៗ ឡើងមកនេះទៅ នៅពួកខ្ញុំនៅនោះ ។

ដានីៈ តាស៊ុន ប្រធានវរសេនាធំឯករាជ្យ?

សែនៈ បាទ!

ដានីៈ មិនមែននៅកងពល៨០១? មិនមែននៅក្នុងកងពលតាហឿន?

សែនៈ អត់ទេ ។

ដានីៈ គាត់ដាច់ពីតាស័ន ដែរ?

សែនៈ ដាច់ ។

ដានីៈ វរសេនាធំឯករាជ្យ?

សែនៈ បាទ! នៅតាកែវ ។

ដានីៈ នៅជាមួយតាកែវ?

សែនៈ បាទ! តាស៊ុន មកខ្ញុំនៅជាមួយតាកែវ ។

ដានីៈ ជា កែវ ហ្នឹង?

សែនៈ បាទ!

ដានីៈ គាត់នៅកំពង់ចាមដែរ?

សែនៈ នៅហ្នឹង ធ្វើការហ្នឹង ។

ដានី៖ គាត់នៅខាងក្រោយក្រុបឆ្មារហ្នឹងដែរ?

សែន៖ បាទ!

ដានី៖ ជា កែវ យើងហ្នឹង?

សែន៖ ស្រុកភូមិគាត់មិនដឹងនៅណាទេ ។

ដានី៖ តែគាត់ទៅធ្វើនៅហ្នឹង?

សែន៖ នៅហ្នឹង នៅម្តុំស៊ីងត្រង់ ។

ដានី៖ ហ្នឹងហៅវរសេនាធំលេខប៉ុន្មានទៅ? វរសេនាធំឯករាជ្យ?

សែន៖ នៅ៦២ដដែល តែតាស័ន អស់ហើយ គាត់អស់កំលាំងគាត់ចូលនឹងគេនឹងឯង គាត់មក នៅជាមួយ តាលាង ។ តាលាង យើងកងពល ។

ដានី៖ អ៊ី លាង?

សែន៖ អ៊ុន លាង ។

ដានី៖ អ៊ុន?

សែន៖ បាទ! អ៊ុន លាង ។

ដានី៖ អ៊ី ឬក៏អ៊ុង?

សែន៖ អ៊ុង ។

ដានី៖ អីចឹងដល់ពេលឡើងមកវិញ អំឡើងមកវិញពេលដែលគេប្រគ្រូសប្រគ្រាសហើយយ៉ាង ម៉េចទៅ? ពេលឡើងមកឡើងមកនៅណា?

សែន៖ មកនៅលិច នៅអូរស្វាយ ។

ដានី៖ ជាមួយពូប្រធានភូមិ ពូរ៉ា?

សែន៖ បាទ! នៅជាមួយគ្នា ។

ដានី៖ ពេលឡើងមកពីកំពង់ចាមជាមួយគ្នាដែរ?

សែន៖ អត់ទេ គាត់ឡើងមកមុនខ្ញុំ គាត់មក គេហៅមកធ្វើមេដឹកនាំគេនៅនេះ ធ្វើការលើ ខ្ញុំនៅ នោះ ព្រោះខ្ញុំមិនសំខាន់រឿងវៃទេ សំខាន់ធ្វើនយោបាយ ខ្ញុំមិនដែលវៃតប់ទេ ។

ដានី៖ នៅក្រុបឆ្មារហ្នឹងអត់ដែលទេ?

សែន៖ អត់ គេនាំតែកយើងឲ្យលុយគេទៅ នាំគ្នាដឹកយើងឆ្លងទៅ ។

ដានី៖ ហើយអីចឹងពេលដែលមកដំបូងនៅអូរស្វាយទេ?

សែន៖ បាទ!

ដានី៖ នៅអូរស្វាយនៅម្តុំណាទៅ?

សែនៈ	នៅជាប់នឹងផ្លូវឡានៗ

ដានីៈ	កាលហ្នឹងប្រពន្ធកូនមកជាមួយគ្នាទាំងអស់គ្នា?

សែនៈ	មុនដំបូងអត់មកទេមកតែខ្ញុំ ទៅធ្វើការនេះ ដល់ផ្តាច់ខ្លួនហើយហៅមកៗ

ដានីៈ	អីចឹងមកនេះបានប៉ុន្មានឆ្នាំបានទៅហៅប្រពន្ធ កូនមកវិញ?

សែនៈ	ប្រហែលកន្លះឆ្នាំៗ

ដានីៈ	ទៅយកមក ឬទៅហៅគាត់មក?

សែនៈ	ទៅហៅមក គេនាំមកតាខាងស្រុក តាពិន គាត់នៅធ្វើការនោះគាត់នាំមក ខ្ញុំទៅយកត្រឹមផ្លូវ១២ៗ

ដានីៈ	ផ្លូវ១២នៅណា?

សែនៈ	ផ្លូវ១២ពីខេត្តព្រះវិហារទៅ ជិតចំការកៅស៊ូៗ

ដានីៈ	តាពិន គាត់ធ្វើអី?

សែនៈ	តាពិន កាលនោះគាត់វរសេនាធំដែរៗ

ដានីៈ	គាត់វរសេនាធំដែរ?

សែនៈ	បាទ!

ដានីៈ	នៅក្នុងកងពលណា?

សែនៈ	នៅជាមួយតាហឿនៗ

ដានីៈ	អ៊ំធ្លាប់ទៅនៅលើប្រាសាទព្រះវិហារ?

សែនៈ	នៅៗ

ដានីៈ	ឆ្នាំណាហ្នឹង? អ៊ំថាតាំងពីឆ្នាំ៨៦អ៊ំទៅនោះរហូត?

សែនៈ	ខ្ញុំវៃតាជាមួយអ៊ីង លាង ទៅនៅនោះ បានខ្ញុំចុះទៅ អេ៎! មិនមែនទេៗ

ដានីៈ	ឆ្នាំ៨៦អ៊ំថាទៅជួយថៃវៃយួនទៅភ្នំបុស្ស វៃភ្នំបុស្សហើយត្រឡប់មកស៊ឹងចាន់ ចេញពីស៊ឹងចាន់គេបញ្ជូនទៅកំពង់ចាម នៅកំពង់ចាមរហូតដល់ឆ្នាំ៩៧-៩៨បានគេហៅឡើងមកវិញ?

សែនៈ	ហ្នឹងហើយ ហៅទៅវៃជាមួយថៃ ដូច៨៥ ឈរវៃហ្នឹង វៃហើយបានទៅក្នុង ទេកាលហ្នឹងផ្តាច់ខ្លួន មិនដឹងណាទេទៅវៃៗ គេវៃនោះហើយ គេវៃនេះដល់ពេលខាងក្នុងគេទៅវៃទៀត បានខ្ញុំទៅជួយវៃគេ ខ្ញុំឡើងខាងក្រោយ ខ្ញុំមិនមែនអ្នកវៃទេ ខ្ញុំវៃតែឡើងក្រោយៗ

ដានីៈ	ឆ្នាំណា? គេវៃឆ្នាំណា?

សែនៈ ឆ្នាំប៉ុន្មាន ខ្ញុំនៅក្នុងមិនដឹង ។

ដានីៈ តែហ្នឹងប្រាសាទព្រះវិហារវ៉ៃកងពលតាហឿនទេ?

សែនៈ បាទ! ស្លាប់ម្នាក់ ។

ដានីៈ ស្លាប់ពីណា?

សែនៈ អត់ស្គាល់ទេ គេអ្នកវ៉ៃខ្ញុំនៅក្នុងនោះដែរ ។

ដានីៈ អ៊ីដល់ពេលមកនៅអូរស្វាយហើយ នៅរហូតដល់ពេលគេធ្វើសមាហរណកម្ម បានត្រឡប់មកនៅនេះឬយ៉ាំងម៉េច?

សែនៈ ធ្វើសមាហរណកម្មមកនៅនេះ នៅនេះបានធ្វើសមាហរណកម្ម កាលគេចាប់វ៉ៃគ្នានោះ ខ្ញុំទៅនោះ ទៅជួយទៅវ៉ៃទៅជាមួយតាស៊ុន ហើយតាម៉ុក គេទៅនៅដីថៃ រាជរដ្ឋាភិបាលបញ្ជូនកំលាំងមកទៅវ៉ៃ ពួកខ្ញុំក៏នាំទៅវ៉ៃលើនោះ ។

ដានីៈ ទៅវ៉ៃតាម៉ុក?

សែនៈ ហ្នឹងហើយ ។

ដានីៈ នាំកំលាំងរដ្ឋាភិបាល? តាកែវ គាត់មកវិញ?

សែនៈ ហ្នឹងហើយ ។ ដល់ពេលវ៉ៃបានហើយ បានផ្តាច់ខ្លួន ។ ផ្តាច់ខ្លួនហើយមិនទាន់នេះទេ មិនទាន់អស់ទេនៅទៀត ដល់ដែនការគេវ៉ៃធំ គេថាមានរថក្រោះដែរ គេថាបបួលថៃវ៉ៃ គេនាំមកនៅនេះ វ៉ៃគ្នានៅតាមអន្លុភាព ខ្ញុំចូលទៅ៨០១វិញ មកនៅនេះវិញ ។

ដានីៈ ដល់អ៊ីចឹងផ្តាច់ខ្លួនចូល៨០១វិញ?

សែនៈ បាទ!

ដានីៈ គេចាប់តា០៥នៅ?

សែនៈ ចាប់ គាត់ស្លាប់ហើយ ។

ដានីៈ គាត់ស្លាប់ហើយបានចូល៨០១វិញ?

សែនៈ បាទ!

ដានីៈ វរៈឯករាជ្យហ្នឹងឈប់ហើយ?

សែនៈ បាទ! ផ្តាច់ខ្លួនមកនៅហ្នឹងរហូត ។

ដានីៈ នៅហ្នឹងវរសេនាធំរបស់ពីណាគេ? នៅមុំភូមិយើង? ពីណាប្រធាន?

សែនៈ តាស៊ុន ។

ដានីៈ ណាផ្ទះគាត់?

សែនៈ នៅទួលតាសេង គាត់ឈប់នៅនេះ ។

ដានី៖ គាត់ទៅនៅទួលតាសេងវិញ?

សែន៖ បាទ! ឥឡូវបែកអស់ហើយ តែកាលនោះគាត់នៅកងពលជាមួយតាអ៊ីង លាង គាត់ចាប់ដីនោះគាត់នៅនោះទៅ ពួកខ្ញុំនៅនេះ ពីមុនដីគាត់នៅនោះទួលត្រង់នោះ គាត់ចាប់ដីនោះគាត់នៅនោះទៅ ។

ដានី៖ អ៊ំដល់ពេលផ្ដាច់ខ្លួនហើយធ្វើអីទៀត?

សែន៖ អត់មានធ្វើអី ឈប់ធ្វើអី ។

ដានី៖ ឈប់ធ្វើទាហានហើយ?

សែន៖ បាទ! ឈប់ហើយ កាត់ ។

ដានី៖ តែដំបូងពីផ្ដាច់ខ្លួននៅធ្វើទាហានជាមួយក្រុម?

សែន៖ បាទ!

ដានី៖ ធ្វើទាហានជាមួយកងពលរបស់ពីណាគេ?

សែន៖ នៅជាមួយតាស៊ុន ដដែល ។

ដានី៖ តាស៊ុន, អ៊ីង លាង ដដែលហ្នឹង?

សែន៖ បាទ! រហូតដល់គេកាត់ ។

ដានី៖ ធ្វើទាហាននៅនេះទេ អត់មានទៅណាទេ?

សែន៖ អត់ទៅណាទេ នៅហ្នឹងរហូត ។

ដានី៖ ដល់ឆ្នាំណាបានគេកាត់?

សែន៖ កាត់ឆ្នាំ ។

ដានី៖ យូរហើយ ឬទើបតែកាត់?

សែន៖ យូរហើយ កាត់វគ្គទី២ គេកាត់សាកល្បងលើកទី១ ខ្ញុំកាត់លើកទី២ ។

ដានី៖ ដល់អាយុគេកាត់ឬយ៉ាងម៉េច?

សែន៖ បាទ! ដល់អាយុកាត់ ។

ដានី៖ តែឥឡូវអ៊ំមានប្រាក់ខែដែរ?

សែន៖ បានប្រាក់ខែ ឥឡូវគេប្រគល់ទៅខាងអេស៊ីលីដា ។

ដានី៖ ខាងណាវិញ?

សែន៖ ខាងអេស៊ីលីដា ។

ដានី៖ ដល់ពេលគេប្រគល់ទៅឲ្យអេស៊ីលីដាបានបើកប្រាក់ខែទៀងទាត់ទេ?

សែន៖ មិនដឹងម៉េច មិនទាន់បានបើកផង ខែមួយបានបើក ។

ដានី:	ខែ១២នេះបើកនៅ?

សែន:	នៅ ខែ១២នេះនៅកិច្ចការនារីដដែល ។

ដានី:	ខាងសង្គមកិច្ច?

សែន:	បាទ! សង្គមកិច្ច ។

ដានី:	ប្រាក់ខែប៉ុន្មានទៅ?

សែន:	ខ្ញុំ៨-១០ម៉ឺន តែឥឡូវគេប្រគល់ទៅហ្នឹងគេកាត់កូន២ចេញទៀតមិនដឹងនៅសល់ប៉ុន្មាន កូននៅក្នុងបន្ទុកដដែល ។

ដានី:	គេកាត់ដំបូងគេឲ្យលុយយើងដែរ?

សែន:	ឲ្យជិត១លានមុនដំបូង នៅខ្វះប៉ុន្មានមួយពាន់ជាងបាន១លាន គេឲ្យម៉ាស៊ីនដេរ បានម៉ូតូមួយ ។

ដានី:	បានម៉ូតូមួយដែរ?

សែន:	បាទ! បានមុង ភួយ កាំបិត ពូថៅ ចប គ្រប់របស់គេ ។

ដានី:	អ៊ំយើងអត់សំរេចចិត្តទៅស្រុកកំណើតវិញទេ?

សែន:	ទៅក៏លំបាកដែរវាក្រដីដែរ បងខ្ញុំបបួលទៅ ខ្ញុំទៅមើល២ដង ដីវាមិនទំនង ឃើញតែគេដើរត្បាតតាមដងទន្លេ ។

ដានី:	ដើរត្បាតម៉េច?

សែន:	មួយខែម្តង ទាហានយួន គេដើរតាមមាត់ទន្លេ មួយខែម្តងៗ ។

ដានី:	នៅខាងស្រុកលោកពូ?

សែន:	ស្រុកប្អូននៅ ។

ដានី:	នៅជាប់ហ្នឹងនៅជាប់ព្រំដែន?

សែន:	បាទ! ព្រំដែនពីដើមឆ្ងាយណាស់ បើថាដើរ២ថ្ងៃអីមិនទាន់ផុត ។

ដានី:	ឥឡូវជិត?

សែន:	ឥឡូវជាប់គ្នា ជាប់ភូមិកំណើតខ្ញុំពីដើម ភូមិកែត កន្លែងកន្ទុយនាគហ្នឹងគេកាត់គំរីម កន្ទុយនាគ គេថាកាត់ តែភូមិនោះគេកាន់អត្តសញ្ញាណបណ្ណខាងនោះអស់ហើយ ។

ដានី:	អ៊ំពេលយើងមកនៅនេះយើងជនជាតិអត់បានធ្វើអីតាមប្រពៃណីជនជាតិ អ៊ំធ្វើអីដែរឬយ៉ាងម៉េចដែលនៅនេះ?

សែន:	រឿងបុណ្យទានខ្ញុំកាន់ដូចនោះ ។

ដានី:	ដូចណា?

សែនៈ ដូចចិន ដល់ពេលសែនចិនៗ ។

ដានីៈ ដូចចិនដែលខាងអី?

សែនៈ ខ្ញុំបើថាមិនធ្វើអត់បានទេ ឈឺ ហ្នឹងវាមិនដឹងមែនឬមិនមែនទេ បើយើងមិនធ្វើចេះតែមានបញ្ហា ។

ដានីៈ ចុះហូបចុកអីយើងនៅប្រកាន់ទំនៀមទំលាប់ហូបចុក?

សែនៈ អត់អីទេ ។

ដានីៈ ហូបចុកដូចខ្មែរយើង?

សែនៈ បាទ!

ដានីៈ ចារ៉ាយគ្រាន់យើងកាន់សាសនាអីដូចរបៀបខាងចាមដែលអត់ទេ?

សែនៈ ដូចអត់ទេ ។

ដានីៈ អ៊ំពិសារសាច់ជ្រូកអីដែលអត់?

សែនៈ សាច់ជ្រូកហូបទាំងអស់ ។

ដានីៈ នៅខាងស្រុកភូមិគេហូបដែល?

សែនៈ ទាំងអស់ហ្នឹងស្រុកភូមិនេះ អត់មានប្រកាន់ទេ ។

ដានីៈ អត់មានតមទេ?

សែនៈ អត់ទេ ។

ដានីៈ ដល់ពេលបុណ្យទានអីស្រដៀងចិនវិញ?

សែនៈ បាទ!

ដានីៈ ចូលឆ្នាំចិនអីហ្នឹង?

សែនៈ បាទ! គេចូលឆ្នាំខែ១ ។

ដានីៈ ដល់ពេលអ៊ំនៅកាលជំនាន់៣ឆ្នាំ ជំនាន់តស៊ូយើងមានធ្វើបុណ្យសែនតាមប្រពៃណី?

សែនៈ អត់បាន ។

ដានីៈ អ៊ំចាប់ផ្តើមធ្វើ ចាប់ផ្តើមសែន ចាប់ពីពេលណា?

សែនៈ ចាប់ពីចប់ ចប់សង្គ្រាម ផ្តាច់ខ្លួន ។

ដានីៈ ផ្តាច់ខ្លួនមកហ្នឹងចាប់ផ្តើមធ្វើឡើងវិញ?

សែនៈ បាទ! កាលធ្វើទាហានគេរៀនគ្រូក៏ខ្ញុំអត់រៀនដែរ អត់មានអីទេ មិនហៅរកទេ ។

ដានីៈ ធ្វើទាហានអ៊ំអត់មានត្រូវរបួសទេ?

សែនៈ អត់ទេ សង្គ្រាម៤ឆ្នាំអត់ត្រូវគ្រាប់ ទាហានរត់ព័ទ្ធជុំវិញវាដេញឯងកិតៗ គ្រាប់បែកនឹងចង្កេះសុខចិត្តស្លាប់ជាមួយគ្នា អត់ឲ្យចាប់ គ្រាប់បែកស្ពាយចេញពីចង្កេះរត់ជង លឺសូរផេះ វាក្រាប ខ្ញុំប្រុចលោតទឹកអូរ ។

ដានីៈ ពីណាដេញតាម?

សែនៈ ទាហានលន់ នល់ ពីដើម បានថាទឹកដោះម្តាយថ្ងៃអត់មានផ្ទុះនៅជាប់នឹងចង្កេះ ។

ដានីៈ នៅនឹងជាប់ចង្កេះហ្នឹងទៅ?

សែនៈ បាទ!

ដានីៈ ប្រពន្ធអ៊ីគាត់ខ្មែរអត់មានកាន់អីតាមអ៊ំទេ?

សែនៈ ខាងនេះ បងថ្ងៃគេកាន់ ដល់ពេលខ្ញុំកាន់រហូត ដល់កូនខ្ញុំជាអ្នកកាន់ ។

ដានីៈ អ៊ំមានបង្រៀនភាសាចារ៉ាយដល់កូនអត់?

សែនៈ អត់ សួរដែលប្រាប់វាមួយម៉ាត់ ថ្ងៃណាវាសួរប្រាប់ទៅ ។

ដានីៈ នាំកូនទៅលេងបងប្អូននៅរតនគិរីដែរ?

សែនៈ ទៅលេង កូនគេទៅនៅខ្លះ២ខែ ទៅលេង ឲ្យកូនទៅនៅអត់ចេះនៅ ។

ដានីៈ អត់ចេះនៅនោះដែរ?

សែនៈ វាចង់នេះដែរ តែមិនបាច់នៅទេ នៅអត់ធ្វើអីដដែល ។

ដានីៈ មកនេះវិញ?

សែនៈ មកវិញ ។

ដានីៈ អ៊ំនេះមានដីធ្វើស្រែ ធ្វើចំការ?

សែនៈ ដីខ្ញុំមិនអត់ទេ ។

ដានីៈ មានច្រើនដែរ?

សែនៈ បាទ! ដីខ្ញុំនេះ នៅលើទួលនោះក្បាល៤០ បណ្តោយជិត២០០ នៅស្រែខ្ញុំនោះ ទួលជាប់ ១០០ក្បាល ហើយបណ្តោយជាប់២០០ ។

ដានីៈ តែអ៊ំខាងព្រះពុទ្ធអីអ៊ំអត់មានចូលទេ?

សែនៈ អត់ ។

ដានីៈ វត្តអត់ទៅ?

សែនៈ ទៅ ថ្ងៃសីលទៅ តែខ្ញុំវាលំបាក ខ្ញុំថាទៅតែសីល៥ កុំឲ្យគេខឹង ។

ដានីៈ អីចឹងប្រពៃណីខាងអ៊ំក៏អ៊ំធ្វើ ខាងខ្មែរក៏ធ្វើ?

សែនៈ បាទ!

ដានី៖ ទៅវត្ត?

សែនៈ ទៅវត្ត ។

ដានី៖ លោកសង្ឃអត់អីទេ?

សែនៈ លោកសង្ឃនិមន្តបិណ្ឌបាតអី កូនអ្នកទៅ ខ្ញុំធ្វើបាយ ។

ដានី៖ កាលពីមុន កាលអ៊ំនៅស្រុកភូមិអី ខាងព្រះពុទ្ធទៅដែរខាងស្រុកភូមិអ៊ំ?

សែនៈ ទេ ខាងនោះអត់មានទេ មានតែមេកន្ទ្រាញមួយទេ ខាងនោះមានសាលាដូចថាវត្តដល់ថ្ងៃគេទៅធ្វើបុណ្យ ថ្ងៃសីលធ្វើតាមផ្ទះ ដាំបាយធម្មតា ដល់ថ្ងៃគេធ្វើពិធីបុណ្យនៅវត្តនាំគ្នាទៅដល់ខែ១គេលាងព្រះ ចូលឆ្នាំលាងព្រះ គេតែងផ្ទះជុំវិញ ។

ដានី៖ មានព្រះដែរ?

សែនៈ មាន ។

ដានី៖ ព្រះអីគេ?

សែនៈ ព្រះ វាមិនមែនរូបអីចឹងទេ ថ្មខ្លះរាងរូប ។

ដានី៖ ដល់ពេលអ៊ំមកនេះទៅវត្តតាមនេះ តាមបងប្អូនខ្មែរ?

សែនៈ តាមបងប្អូនខ្មែរហ្នឹង ខ្ញុំដាក់ក្នុងប្រវត្តិរូបក៏ដាក់ជនជាតិខ្មែរ ។

ដានី៖ អត់ដាក់ចារ៉ាយ?

សែនៈ អត់ ដូចកូនខ្ញុំខ្លះគេកើតណាដាក់ត្រង់ហ្នឹង ខ្ញុំខ្ជិល ដាក់តែទំនប់ដាច់មួយ ខ្ជិលចាំកើតនេះនោះ ។

ដានី៖ អ៊ំបើនិយាយពីជីវិតអ៊ំដែលអ៊ំឆ្លងកាត់តាំងពីក្មេង នៅរតនគិរី ដល់ជំនាន់សង្គ្រាមយើងរត់ហូរហែរតាមគ្រប់កន្លែង ហើយក្រោយមកយើងផ្លាច់ខ្លួនយើងរស់នៅនេះ តើយ៉ាងម៉េចដែរជីវិតអ៊ំប្រៀបធៀបមើល តាំងពីដើម តាំងពីក្មេង ពេលសង្គ្រាមយ៉ាងម៉េចហើយក្រោយមកយ៉ាងម៉េចបើប្រៀបធៀបទៅ ខុសគ្នាយ៉ាងម៉េចខ្លះ?

សែនៈ បើការពិសោធន៍ខ្ញុំប៉ុន្មានជំនាន់ឃើញថាចប់អីចឹងក៏ម្យ៉ាងស្រួល ការរកស៊ី ការរស់នៅ នៅតែខ្លួនផ្ទាល់ក្នុងការអនុវត្តខំប្រឹងប្រែងរកស៊ី ខំកាលណាបានកាលនោះ ធ្វើអីក៏បានបើយើងមិនប្រឹងក៏វាក្រខ្លួនឯង ដូចថាវាសប្បាយចិត្តម្យ៉ាង តែខ្ញុំវាគ្មានស្អីទេ ឈើក៏ខ្ញុំមិនរក ខ្ញុំមិនដើរជាមួយគេ ហើយម្យ៉ាងខ្ញុំចាស់ហើយធ្វើអីមិនកើត ខ្ញុំដើរទៅអត់មានការងារហើយម្យ៉ាងទៀតនៅអីចឹងទៅស្រួល ដេកក៏លក់ស្រួល ធ្វើការខ្ញុំដាក់ពេលណាក៏បាន យើងមានសិទ្ធិសេរីភាពមួយក៏វាល្អម្យ៉ាងដែរ គ្មានអីរវីរវល់គិតស្មុគស្មាញអីទេ គេនិយាយចេះចុះពីការរស់នៅពីគណបក្សអី អាហ្នឹងម្យ៉ាង ខ្ញុំថាខ្ញុំមិនរវីរវល់ខាងណាច្រើនទៅហ្នឹង ខាង

ណាឈ្នះទៅហ្នឹង ខ្ញុំមិនប្រែប្រួល ហូបបាយអ្នកណាបំរើអ្នកហ្នឹង បើថាខុសពីហ្នឹងតាមកាឡាប់ចក្រ ប្រែប្រួល ។

ដានីៈ ហ្នឹងមួយ តែទាក់ទងរឿងនយោបាយខាងណាក៏បាន ឲ្យតែខាងណាគេចូលចិត្តច្រើនទៅខាងហ្នឹង?

សែនៈ បាទ!

ដានីៈ មិនសង្កត់ធ្ងន់អីទេ ។

សែនៈ បាទ!

ដានីៈ តែខាងនេះខាងគណបក្សប្រឆាំងគេមានចូលមកច្រើនទេ?

សែនៈ ខ្លះគេមាន ។

ដានីៈ ចុះសាសនាអីខាងនេះមានកាន់សាសនាផ្សេងៗក្រៅពីព្រះពុទ្ធ?

សែនៈ អត់មានទេ តែដោយឡែកតែភូមិទៅលិចនោះសាសនាព្រះពុទ្ធដែរ តែធ្វើខុស ។

ដានីៈ នៅណា?

សែនៈ នៅលិច ។

ដានីៈ ភូមិអី?

សែនៈ តាដុង ។

ដានីៈ ឃុំណា?

សែនៈ ភូមិនេះដែរតែវាចែកជាពីរ ដល់ពេលលោកគេមកនៅ គេនាំគ្នាទៅនៅនោះ ។

ដានីៈ ភូមិតាដុង?

សែនៈ បាទ ។

ដានីៈ មានលោកដែរ?

សែនៈ មាន ។

ដានីៈ រួចគេធ្វើខុសម៉េចទៅ?

សែនៈ ខុសរឿងធ្វើការងារដូចសង្គមនិយមអីចឹង មានវេរដួង, ទៅធ្វើការងាររួម ។

ដានីៈ ឥឡូវហ្នឹង?

សែនៈ បាទ! គេធ្វើអីចឹង អ្នកណាមិនប្រើង មិនធ្វើមានទោស ។

ដានីៈ ចុះខាងរដ្ឋអំណាចគេអត់ថាអីទេ?

សែនៈ គេណែនាំ តែនៅតែធ្វើអីចឹង ពីមុនបើធ្វើខុសសុទ្ធតែរត់ប៉ុន្មានជុំសាលា ។

ដានីៈ ប៉ុន្តែយើងស្ម័គ្រចិត្តនៅជាមួយគេទេ?

សែនៈ	គេនៅ គេជឿសាសនា តែព្រះពុទ្ធដូចគ្នា ធ្វើខុសគ្នា ។

ដានីៈ	តែអ៊ឹមកឆ្ងាយអីចឹង ដូចថាមនោសញ្ចេតនា អារម្មណ៍អ៊ឹទាក់ទងពី ដូចថាអ៊ឹមកនៅនេះនៅជាមួយសហគមន៍ខ្មែរយើងដាច់ពីជនជាតិយើង ហើយការរស់នៅរបស់អ៊ឹ អារម្មណ៍អ៊ឹយ៉ាងម៉េចដែរ? ដូចថាកាលពីក្មេងរស់នៅផ្ទះនៅស្រុកភូមិជាមួយបងប្អូនយើង សហគមន៍ជនជាតិយើង ដល់ក្រោយពីមានសង្គ្រាមយើងតស៊ូ យើងចេញមក ហើយឥឡូវនេះយើងមកនៅជាមួយខ្មែរ អារម្មណ៍ការរស់នៅយ៉ាងម៉េចដែរ?

សែនៈ	ធម្មតា អត់មានអី គិតទៅវាដូចតែដូច ការរស់នៅ ការហូបចុកទៅមិនខុសគ្នា គ្រាន់តែលំបាករឿងខ្មែរយើង ជនពាល យ៉ាប់តែប៉ុណ្ណឹងបើខាងអត់ទេ ។

ដានីៈ	បានន័យថា អ៊ឹចង់និយាយថា ខ្មែរហ្នឹងក្មេងៗទំនើង រីតប់ពេលរាំច្រៀង ដូចថាដឹកស៊ីជក់គ្រឿងញៀនផ្តេសផ្តាស?

សែនៈ	បាទ!

ដានីៈ	បើខាងអ៊ឹនៅនោះអត់មាន?

សែនៈ	អត់ទេ ម៉ូតូទុកចោល ភូមិគេខាងនោះទន្លេ គេទុកខាងនេះទន្លេ មួយថ្ងៃវាស់ល្ងាចមិនទៅណាផង ។

ដានីៈ	បើនេះអត់បានទេ?

សែនៈ	មិនបានទេ តែទុកនៅផ្ទះហើយនៅតែយកទៀត ។

ដានីៈ	ឥឡូវក្នុងភូមិហ្នឹង?

សែនៈ	ភូមិហ្នឹងក៏មាន ភូមិផ្សេងក៏មានដូចគ្នា អីចឹងវាលំបាក ។

ដានីៈ	យ៉ាប់រឿងចោរកម្ម?

សែនៈ	បាទ! បើគ្រាន់តែយ៉ាប់ប៉ុណ្ណឹងទេ តែវាគ្មានបញ្ហាទេ ដូនគេក៏គេ ពីដើមខ្ញុំធ្លាប់ណែនាំគេដែរ ណែនាំក្មេងៗការជិះម៉ូតូកុំបង្ហោះ ការនិយាយស្តីដឹងចាស់ ដឹងទុំ និយាយគេ២-៣ដងគេមិនដឹងក៏ឈប់ ។

ដានីៈ	អ៊ឹមានតួនាទីអីដែលសព្វថ្ងៃនេះ?

សែនៈ	អត់ទេ ខ្ញុំឈប់ហើយ មុនខ្ញុំនៅមណ្ឌល ។

ដានីៈ	មណ្ឌលណា?

សែនៈ	មណ្ឌលសុខភាពនេះ ។

ដានីៈ	នៅមណ្ឌលសុខភាពខាងពេទ្យ?

សែនៈ	អត់ទេខ្ញុំខាងមណ្ឌលសុខភាពខាងភូមិ គ្រប់គ្រងភូមិ ឥឡូវឲ្យទៅខាងកូនម្តង ។

ដានី៖ កូនស្រី?

សែន៖ បាទ! ខ្ញុំវាធ្វើការងាររបេះតែឃើត កត់ត្រាមិនសូវទាន់គេ ឲ្យកូនម្តង កាលមុនគេបោះឆ្នោតឲ្យធ្វើប្រធានភូមិ ធ្វើមិនកើត ខ្ញុំកូនប្រុសតែមួយ រវល់តែទៅប្រជុំ អត់មានអ្នកណាទៅភ្ជួរទៅរាស់ ភូមិត្រូវការប្រជុំញឹកញាប់ បើគាត់មានកូនច្រើន កាលមុនកូនគាត់មិនទាន់យកប្រពន្ធ។

ដានី៖ ធ្វើមេភូមិទាល់តែទៅនេះ ទៅនោះ ប្រជុំច្រើន។

សែន៖ បាទ!

ដានី៖ អ៊ីខ្ញុំដូចជាអស់សំនួរអីត្រូវសួរនាំអ៊ំទៀតហើយ អ៊ំមានអីបន្ថែមនូវអ៊ីដែលខ្ញុំអត់ទាន់បានសួរនាំអ៊ំទេ?

សែន៖ អត់មានអីទេ។

ដានី៖ អីចឹងខ្ញុំអរគុណអ៊ំច្រើនដែលផ្តល់ អនុញ្ញាតខ្ញុំសួរនាំអ៊ំទាក់ទងពីជីវិតរបស់នៅរបស់អ៊ំតាំងពីក្មេងរហូតមកដល់ឥឡូវនេះ អរគុណអ៊ំច្រើន។

សែន៖ បាទ! ធ្វើម៉េចផ្តែផ្តាំខុសឆ្គងអីកុំឲ្យមានបញ្ហា ព្រោះការនិយាយទៅវាភ្លេច និយាយទៅមិនចំចំណុច សំដី។

ដានី៖ អ៊ំអត់មានអីទេ អត់មានខុសឆ្គងអីទេ ពួកខ្ញុំជាអ្នកប្រវត្តិសាស្ត្រទេ អីចឹងអរគុណអ៊ំច្រើនម្តងទៀត។

សែន៖ បាទ!

**ចប់**